ខេមា មីក្រូហិរញ្ញវត្ថុ
CAMMA MICROFINANCE

# របាយការណ៍ប្រចាំឆ្នាំ
# Annual Report
# 2018




www.camma.com.kh

Camma Microfinance Limited

ខេមា មីក្រូហិរញ្ញវត្ថុ

CAMMA MICROFINANCE

# របាយការណ៍ប្រចាំឆ្នាំ
# ២០១៨

# មាតិកា


ទស្សនៈ វិស័យ និង បេសកកម្ម......ព
សារតារបស់ ខេមា ......៣
គុណតម្លៃស្នូល ......៤
ម្ចាស់កម្ចី និងដៃគូ ......៥
សារលិខិតពីប្រធានក្រុមប្រឹក្សាភិបាល......៦
ចំណាប់អារម្មណ៍របស់អគ្គនាយិកាប្រតិបត្តិ ......៨
វិសាលភាពប្រតិបត្តិការ......១០
សមិទ្ធផលសំខាន់ៗ ......១១
អំពីអតិថិជន ......១៤


## អភិបាលកិច្ច


គណៈគ្រប់គ្រង ......១៨
បុគ្គលិកគ្រប់គ្រង......២២
រចនាសម្ពន្ធគ្រប់គ្រង ......២៣
ផលិតផល និងសេវាកម្ម ......២៤
សង្ខេបសកម្មភាពទីផ្សារ ......២៦


## ការកសាងសមត្ថភាពបុគ្គលិក


ការលើកទឹកចិត្តបុគ្គលិកលើសមិទ្ធផល ......២៨
ការអភិវឌ្ឍចំណេះជំនាញដល់បុគ្គលិក ......២៩
សុខុមាលភាពរបស់បុគ្គលិក ......៣០
ការផ្ដល់ឱកាសដល់និស្សិតចុះកម្មសិក្សា......៣១
ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង......៣២
ការទទួលខុសត្រូវចំពោះសង្គមនិងបរិស្ថាន ......៣៤
របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ......៣៦
របាយការណ៍របស់សវនករឯករាជ្យ ......៤០


## របាយការណ៍ហិរញ្ញវត្ថុ


តារាងតុល្យការ ......៤៤
របាយការណ៍លទ្ធផល ......៤៥
របាយការណ៍លំហូរទឹកប្រាក់......៤៦
របាយការណ៍បម្រែបម្រួលមូលធន......៤៧

# ទស្សនៈវិស័យ និង បេសកកម្ម

## ទស្សនៈវិស័យ

ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏មានទំនុកចិត្តមួយ ដែលផ្តល់ឱកាសឲ្យប្រជាពលរដ្ឋកម្ពុជាក្នុងការកែលម្អជីវភាពរស់នៅតាមរយៈការ ទទួលយកសេវាឥណទានពី គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។

## បេសកកម្ម

ផ្តល់សេវាមីក្រូហិរញ្ញវត្ថុដ៏ធំទូលាយដល់ សហគ្រិនខ្នាតតូច និងមធ្យម ដែលជា ប្រជាកសិករ សិប្បករ និងពាណិជ្ជករ ប្រកបដោយសមត្ថភាព និរន្តរភាព និងធានាបាននូវអត្ថប្រយោជន៍ខ្ពស់ ជូនភាគទុនិក បុគ្គលិក និងសង្គមជាតិទាំងមូល។

# សារគារបស់ ខេមា

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ត្រូវបានផ្តួចផ្តើមគំនិត និងបង្កើតឡើងដោយស្ថាបនិកពីររូបគឺលោកស្រី **អ៊ូ សាន** និងលោកស្រី **ឱត នីតា** នៅក្នុងឆ្នាំ២០០៨ ដែលក្នុងពេលនោះខេមាគឺជាប្រតិបត្តិករ ឥណទានឯកជនមួយ ដែលបានធ្វើ ប្រតិបត្តិការ និងសេវាផ្តល់ឥណទានជូនប្រជាពលរដ្ឋកម្ពុជាក្នុងរាជធានីភ្នំពេញ និង ខេត្តកណ្តាល ។

តម្រូវការឥណទាន ដើម្បីពង្រីកអាជីវកម្ម និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ អតិថិជនដែលទទួលបានឥណទានក៏មានជីវភាពធូរធារ និងមានការអភិវឌ្ឍជាលំដាប់។ ដើម្បីឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានរបស់អតិថិជន ក៏ដូចជាចូលរួមចំណែកកាត់បន្ថយនូវភាពក្រីក្រ របស់ប្រជាពលរដ្ឋ វាចាំបាច់តម្រូវឲ្យខេមាពង្រីកវិសាលភាព បង្កើនទំនុកចិត្ត ភាពជឿជាក់ និងពង្រឹងគុណភាពនៃប្រតិបត្តិការរបស់ខ្លួន ។

កត្តាទាំងនេះជំរុញឲ្យស្ថាបនិកទាំងពីរ រៀបចំខេមាឲ្យក្លាយពីប្រតិបត្តិករឥណទានឯកជនមកជាគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដ៏មានទំនុកចិត្តមួយ តាមរយៈការចុះបញ្ជី ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ជាមួយក្រសួងពាណិជ្ជកម្ម ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.0700 KH/2010 នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១០ ជាមួយនឹងដើមទុនចុះបញ្ជីចំនួន ២០០.០០០ (ពីររយពាន់) ដុល្លារអាមេរិក។

នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១០ គ្រឹះស្ថានខេមាទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិ នៃកម្ពុជា គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានសិទ្ធិពេញលេញក្នុងការផ្តល់ឥណទានជូនអតិថិជន។ ខេមាចាប់ផ្តើមធ្វើ ប្រតិបត្តិការផ្តល់ឥណទាន ជាផ្លូវការចាប់ពីថ្ងៃទទួលបានអជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា។ ខេមា បានរៀបចំខ្លួនឲ្យក្លាយជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ លីមីតធីត ដែលមានអភិបាលកិច្ចល្អ មានប្រព័ន្ធស្តង់ដារការងារត្រឹមត្រូវ និងមានគោលការណ៍ការពារអតិថិជនច្បាស់លាស់ ។ នៅឆ្នាំ ២០១៥ ខេមាបានបង្កើនដើមទុនចុះបញ្ជីដល់ចំនួន ២.១០៣.០០០ (ពីរលានមួយរយបីពាន់) ដុល្លារអាមេរិក។ ក្នុងឆ្នាំ២០១៩ ខាងមុខនេះ ភាគទុនិកមានគម្រោងបង្កើនដើមទុនចុះបញ្ជីបន្ថែមទៀតដែល
មានទឹកប្រាក់ ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

តាមរយៈបណ្តាញប្រតិបត្តិការសាខាចំនួន ៣ និងបុគ្គលិក ៩៥រូប (គិតត្រឹមខែធ្នូ ឆ្នាំ២០១៨) ខេមាបាន នឹងកំពុងបម្រើអតិថិជនប្រមាណជាង ១.៦៤៩នាក់ ជាមួយនឹងសំពៀតឥណទាន ១០.៣៣៤.៦៤៨ ដុល្លារអាមេរិក នៅថ្ងៃខាងមុខ ខេមា នឹងបន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួននៅតាមជនបទ និងទីប្រជុំជន ហើយនឹងអភិវឌ្ឍន៍ផលិតផល និងសេវាហិរញ្ញវត្ថុថ្មីៗ សម្រាប់បំពេញតម្រូវការរបស់អតិថិជន ជាមួយនឹងគណៈគ្រប់គ្រងដែលមានបទពិសោធន៍ជាច្រើនឆ្នាំ អភិបាលកិច្ចដ៏រឹងមាំ និងការប្តេជ្ញាចិត្តក្នុងសកម្មភាពសង្គម។ ខេមា បានត្រៀមខ្លួនជាស្រេចក្នុងការបន្តពង្រីកបណ្តាញប្រតិបត្តិការ និងឥទ្ធិពលរបស់ខ្លួននៅទូទាំងប្រទេស។

# គុណតម្លៃស្នូល

បុគ្គលិកគ្រប់លំដាប់ថ្នាក់របស់គ្រឹះស្ថាន ខេមា ផ្តល់នូវសេវាកម្មដ៏ល្អបំផុតជូនអតិថិជនប្រកបដោយភាពស្មោះត្រង់ តម្លាភាព និងដោយការគោរព។

## សេវាកម្មល្អបំផុត

ផ្តល់នូវសេវាកម្មដ៏ល្អបំផុតប្រកបដោយសមភាព ប្រសិទ្ធភាព និងរហ័សទាន់ចិត្តជូនអតិថិជន។

## ភាពស្មោះត្រង់

ភាពស្មោះត្រង់របស់បុគ្គលិកគ្រប់លំដាប់ថ្នាក់ក្នុងការផ្តល់សេវា និងផលិតផលហិរញ្ញវត្ថុជូនអតិថិជនទាំងក្នុង និងក្រៅគ្រឹះស្ថានប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈ។

## តម្លាភាព

ផ្តល់ព័ត៌មានអំពីផលិតផល សេវាកម្មជូនអតិថិជនឲ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដើម្បីឲ្យអតិថិជនបានយល់ច្បាស់អំពីផលិតផល និងសេវាកម្មរបស់គ្រឹះស្ថាន។

## ការគោរព

បុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រកាន់ភ្ជាប់នូវភាពថ្លៃថ្នូរ រួសរាយរាក់ទាក់ គោរពគ្នាទៅវិញទៅមក គោរពអតិថិជន និងយល់អំពីស្ថានភាពរបស់អតិថិជន។

# ម្ចាស់កម្មវិធី និង ដៃគូ

| | |
|---|---|
| ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | ANZ Royal Bank (Cambodia) Limited |
| ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ធនាគារ វឌ្ឍនៈ | Cathay United Bank |
| ធនាគារ ហ្វីលីព ភីអិលស៊ី | ក្រេឌីតប្យូរ៉ូកម្ពុជា (ស៊ីប៊ីស៊ី) |
| សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (ស៊ីអឹមអេ) | Good Return |
| ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត | |

# សារលិខិតពី ប្រធានក្រុមប្រឹក្សាភិបាល



លោក **ធន់ ចន្ថុនា**
ប្រធានក្រុមប្រឹក្សាភិបាល

អស់រយៈពេលជិត ៩ឆ្នាំ មកនេះគ្រឹះស្ថាន ខេមា មី ក្រូហិរញ្ញវត្ថុ លីមីតធីត បានឆ្លងកាត់ពេលវេលាល្អៗ និង លំបាកជាច្រើន។ សម្រាប់ឆ្នាំ២០១៨ នេះខ្ញុំមានក្តីសោមនស្សរីករាយបំផុតនឹងបង្ហាញជូនលោក លោកស្រីអំពីរបាយការណ៍ប្រចាំ ឆ្នាំ២០១៨ របស់ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។ នៅក្នុង របាយ ការណ៍នេះនឹងបង្ហាញជូន ពីសមិទ្ធិផលនានា របស់ ខេមា ដែលសម្រេចបានក្នុងឆ្នាំនេះ ដោយរួម បញ្ចូលទាំងពិពណ៌នាពីភាពជោគជ័យ របស់អតិថិជន នៅតាមតំបន់គោលដៅដែលលទ្ធផលនៃការខិតខំប្រឹង ប្រែង តស៊ូ ពុះពារ ឆន្ទៈ និងការប្តេជ្ញាចិត្តក្នុងការជួយ ឲ្យសេដ្ឋកិច្ច ប្រជាពលរដ្ឋកម្ពុជានៅតាមសហគមន៍ និងអតិថិជនរបស់ខ្លួនដែរ។ វាមិនគួរឲ្យភ្ញាក់ផ្អើល នោះទេវាបានជំរុញការប្តេជ្ញាចិត្ត និងខិតខំប្រឹងប្រែង ព្យាយាមក្នុងការនាំយកសេវាមីក្រូហិរញ្ញវត្ថុ ទៅដល់ ដៃអតិថិជនរបស់យើង។ សម្រាប់ឆ្នាំ២០១៨នេះដែរ វាបានបង្ហាញពីសន្ទានុពល នៃកំណើនសេដ្ឋកិច្ចរបស់ ប្រទេសកម្ពុជាប្រចាំឆ្នាំគឺ មានកំណើនក្នុងអត្រា ៦,៩% (IMF World Economic Outlook 2016) ប្រហាក់ ប្រហែលគ្នាបើធ្វើការប្រៀបធៀបទៅនឹង ឆ្នាំ២០១៧។ កំណើននេះបាន ធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេស មួយដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនជាងគេក្នុង ចំណោមប្រទេសនានាក្នុងពិភពលោក។ ហើយវានឹង កើនឡើង ៧,0% (២០១៩) និង ៦,៨% (២០២០) ជាមួយនឹងអតិផរណានេះដែលបានរំពឹងទុក ២,៥% (២០១៩) និង (២០២០)។ ទាំងនេះសបញ្ជាក់ថា កម្ពុជានៅតែបន្តជំហានជាវិជ្ជមាននៅក្នុង ការលើកស្ទួយ សេដ្ឋកិច្ចជាតិទាំងមូល។ ជាក់ស្តែងឆ្នាំ២០១៨គឺជា ឆ្នាំដែលអ្នកពាក់ព័ន្ធទាំងអស់បានបញ្ជាក់ ឡើងវិញ អំពីការខិតខំប្រឹងប្រែងព្យាយាម និងការប្តេជ្ញាចិត្ត ចំពោះគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដែល បានបង្កើតឡើងដោយស្ថាបនិករបស់ខ្លួនជាមួយ នឹង ជំនឿយ៉ាងមុតមាំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែល រឹងមាំ និងប្រកួតប្រជែងអាចជាស្ថាប័នមួយដែលប្តេជ្ញា ចិត្តកាត់បន្ថយភាពក្រីក្រនៅក្នុង សហគមន៍កម្ពុជា ទាំងមូល។ទន្ទឹមគ្នានេះផងដែរការពង្រឹងផលិតភាព និងប្រសិទ្ធភាពអាចសម្រេចទៅបាន លុះត្រាតែបុគ្គលិក ទាំងអស់ស្រលាញ់រាប់អាន និងជួយគ្នាទៅវិញទៅមក ព្រមទាំងសហការគ្នាផ្តួចផ្តើមគំនិតច្នៃប្រឌិត និងគំនិត ថ្មីឆ្ពោះទៅពង្រឹងផលិតភាពបុគ្គលិក និងកាត់បន្ថយ ចំណាយប្រតិបត្តិការ និងទុន(កម្ចី)វិនិយោគ។ បើអាច ធ្វើដូច្នេះបាននោះសេវាមីក្រូហិរញ្ញវត្ថុរបស់ ខេមា នឹង បន្តរីកធំធាត់សម្រាប់អតិថិជន ក្នុងតំបន់ប្រតិបត្តិការ បច្ចុប្បន្ន និងឈានទៅពង្រីកតំបន់ប្រតិបត្តិការថ្មីៗ

ថែមទៀតតាមរយៈការពង្រីកបណ្តាញរបស់ខ្លួននិង ការអភិវឌ្ឍន៍នូវផលិតផល ព្រមទាំងសេវាកម្មថ្មីៗ ដើម្បីឆ្លើយតបទៅ នឹងបម្រែបម្រួលនៃតម្រូវការរបស់អតិថិជន។ ខេមា បានប្តេជ្ញាចិត្តដើម្បីគោរពតាម គោលការណ៍ណែនាំផ្តល់ឥណទានជាន់គ្នា ជាច្រើន ស្ថាប័ន និងបន្តអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់ខ្លួនដើម្បី ការកាត់បន្ថយហានិភ័យ តាមរយៈការយកចិត្តទុកដាក់លើការអភិវឌ្ឍសកម្មភាពផ្តល់ឥណទានតាមតំបន់ប្រតិបត្តិការរបស់ខ្លួនដែរ។

យោងទៅតាមផែនការយុទ្ធសាស្ត្រ ប្រចាំឆ្នាំ ២០១៩ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ទំហំឥណទានសរុបត្រូវបានរំពឹងទុកមានរហូត ដល់ ១៣.៥០៥.៦០៧ដុល្លារអាមេរិក នៅចុងឆ្នាំ២០១៩ ហើយនឹងមានចំនួនអតិថិជន ២.៤៩១នាក់ ក្នុងនោះ សម្រាប់គ្រប់ការិយាល័យ-សាខាទាំងអស់ ដូចខាងក្រោមនេះ ៖

- ការិយាល័យប្រតិបត្តិការ ៖ ត្រូវសម្រេចឲ្យបានផែនការសមតុល្យឥណទាន ចំនួន៦.៩២៣.១៩៦ ដុល្លារអាមេរិក អតិថិជនចំនួន ១.២២២នាក់ និង អនុបាតហានិភ័យឥណទានកម្រិតត្រឹមតែ ២,00% (ភាគរយ)។
- សាខាស្រុកអង្គស្នួល ៖ ត្រូវអនុវត្តផែនការឥណទានក្នុងចំនួន ៣.១០០.២១៨ដុល្លារអាមេរិក អតិថិជនចំនួន ៥៧៦នាក់ និងអនុបាតហានិភ័យឥណទាន ១,00% (ភាគរយ)។
- សាខាក្រុងតាខ្មៅ ៖ ត្រូវអនុវត្តផែនការឥណទានក្នុងចំនួន ៣.៤៨២.១៩៣ដុល្លារអាមេរិក អតិថិជនចំនួន ៦៩៣នាក់ និងអនុបាតហានិភ័យ ឥណទាន ២,00% (ភាគរយ)។

ក្រោមការខិតខំប្រឹងប្រែងរបស់បុគ្គលិក និង គណៈគ្រប់គ្រងរបស់គ្រឹះស្ថាន រួមជាមួយនឹងយុទ្ធសាស្ត្រថ្មីដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលនៃ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាយើងសង្ឃឹមយ៉ាងមុតមាំថា យើងនឹងអាចសម្រេចបាន លទ្ធផលដ៏ត្រចះត្រចង់នៅក្នុង ២០១៩ ខាងមុខនេះ ។

ជាទីបញ្ចប់ ជំនួសមុខឲ្យសហភាគទុនិកនិង ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត យើងខ្ញុំសូមសម្តែងនូវគារវកិច្ច និងអរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាល ធនាគារជាតិនៃ កម្ពុជា ភាគទុនិក អតិថិជន និងសាធារណជនទាំង អស់ដែលតែង តែផ្តល់ភាពជឿជាក់មកលើ ខេមា។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណ ចំពោះថ្នាក់គ្រប់គ្រង និងបុគ្គលិក ខេមា ទាំងអស់ដែលបានបន្តប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងបានលះបង់ពេលវេលាដ៏មានតម្លៃ និងកំលាំងកាយចិត្តដើម្បីជួយដល់ ខេមា ឲ្យទទួលបានជោគជ័យ និងសមិទ្ធផលដូចសព្វថ្ងៃនេះ។ លើសពីនេះទៀត ខ្ញុំសូមអរគុណផងដែរ ចំពោះភាគទុនិកទាំងអស់ ក្នុងការបន្តការគាំទ្ររហូតមក។ យើងទាំង អស់ នឹងបន្តវប្បធម៌សហការគ្នាជាធ្លុងមួយ ដើម្បី ធានាថា គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត នៅតែជាស្ថាប័នដែលផ្តល់នូវសេវាកម្មរហ័ស និងល្អបំផុត ហើយនឹងមានទំនួលខុសត្រូវខ្ពស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា និង ទីផ្សារ៕

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់

ធន់ វឌ្ឍនា
ប្រធានក្រុមប្រឹក្សាភិបាល



# ចំណាប់អារម្មណ៍ របស់អគ្គនាយិកា ប្រតិបត្តិ

*លោកស្រី* **ឱត នីតា**
*អគ្គនាយិកាប្រតិបត្តិ*

ក្រោយការបោះឆ្នោតរដ្ឋសភានិតិកាល ទី៦ ក្នុងឆ្នាំ២០១៨ប្រជាជនកម្ពុជាព្រមទាំងអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសមានទំនុកចិត្តខ្ពស់លើស្ថេរភាពនយោបាយក្នុងប្រទេសកម្ពុជា។ គ្រប់វិស័យនៃសេដ្ឋកិច្ចជាតិមានភាពរឹងមាំ និងរីកចំរើន ដែលធ្វើឲ្យកំណើនសេដ្ឋកិច្ចជាតិក្នុងឆ្នាំ២០១៨ ស្ថិតក្នុងអត្រា ៧.៣%។វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុគឺជាចលករមួយសំខាន់ ដែលចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិនេះ។ របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជាក្នុងឆ្នាំ២០១៨ បានបង្ហាញថាទ្រព្យសកម្មរបស់វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុកើនឡើង ១៩.៤% ធៀបនឹងឆ្នាំ២០១៧ (ស្មើនឹង៤០ ប៊ីលានដុល្លារអាមេរិក)។ ឥណទានសរុបក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ មានចំនួន ១៩.៦ប៊ីលានដុល្លារអាមេរិក និង ៥.៤ប៊ីលានដុល្លារអាមេរិក។ ឥណទានទាំងនេះត្រូវបាន ផ្តល់ទៅគ្រប់វិស័យនៃសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងការរីកចំរើននៃវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានខេមាក៏មានការរីកចំរើនគួរឲ្យកត់សំគាល់។ ប៉ុន្តែការដាក់ចេញនូវប្រកាសថ្មីៗរបស់ធនាគារជាតិក៏ដូចជាបទបញ្ញត្តិនានារបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៨ បានធ្វើឲ្យមានឥទ្ធិពលទៅលើលទ្ធផលនៃប្រតិបត្តិការរបស់ខេមា។ លទ្ធផលសំខាន់ៗនៃប្រតិបត្តការត្រូវបានបង្ហាញដូចខាងក្រោម៖

គ្រឹះស្ថានបានបង្កើតនូវផលិតផលឥណទានថ្មីមួយដែលមានឈ្មោះថា ឥណទានយានយន្តដែលអនុញ្ញាតឲ្យអតិថិជនប្រើប្រាស់ ឥណទានសម្រាប់ទិញ ទោចក្រយាន ឬម៉ូតូកង់បី ដើម្បីបម្រើនូវការប្រើប្រាស់ជាប្រចាំថ្ងៃ ក៏ដូចជាសម្រាប់ស្វែងរកប្រាក់ចំណេញ។

ខេមាមានសាខាចំនួន៣ បុគ្គលិកចំនួន ៩៤ នាក់បម្រើអតិថិជនប្រមាណ ១៦៤៩នាក់។ ចំនួនអតិថិជនកើនឡើង ៣៥៦នាក់ ស្មើនឹង ២៩% នៃឆ្នាំ២០១៧។ ក្នុងនោះអតិថិជនជាស្រ្តីមានចំនួន ៤៩% នៃអតិថិជនសរុប។ សមតុល្យឥណទានសរុបមានចំនួនពី ១០,៣៣៤,៦៤៨ ដុល្លារអាមេរិកកើនឡើងប្រមាណ ៣៣.៤១% ធៀបនឹងឆ្នាំ២០១៧។ សមតុល្យឥណទានប្រាក់រៀលចំនួន ៣.២៣% នៃសមតុល្យ

ឥណទានសរុប។ ហានិភ័យឥណទានថយចុះពីចំនួន ២.៧៤% ក្នុងឆ្នាំ ២០១៧ មកត្រឹម ១.៩៥% ក្នុងឆ្នាំ ២០១៨។ ចំណូលការប្រាក់សរុបកើនឡើង ៦% ចំណែកឯប្រាក់ចំណេញក្រោយបង់ពន្ធថយចុះ ១.៤% ។ អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិកជាមធ្យម (Return on Average Equity) បានថយចុះពី ៥.៦៧% ក្នុងឆ្នាំ២០១៧ មក ៥.៥១% ក្នុងឆ្នាំ២០១៨។ ការធ្លាក់ចុះទាំងនេះគឺ បណ្តាលមកពីការដាក់ចេញនូវប្រកាសលេខ ធ៧/០១៨ ០០១ សរចណ របស់ធនាគារជាតិនៃកម្ពុជា ស្តីអំពីការធ្វើសំវិធានធននៃប្រាក់បញ្ញើរបស់គ្រឹះស្ថាន នៅតាមបណ្តាធនាគារ និងប្រកាសលេខ៤៤៣ ក.ប/ប្រ.ក.ខ.ល របស់ក្រសួងការងារស្តីពីការទូទាត់ ប្រាក់បំណាច់អតីតភាពការងារ។ ប្រកាសទាំងនេះបានធ្វើឲ្យប៉ះពាល់ប្រាក់ចំណេញរបស់គ្រឹះស្ថានសម្រាប់ឆ្នាំ ២០១៨ ប្រមាណ ៤២,២៤២ ដុល្លារអាមេរិក។

លទ្ធផលទាំងនេះគូសបញ្ជាក់ឲ្យឃើញថា យុទ្ធសាស្ត្ររបស់ខេមា ក្នុងឆ្នាំ២០១៨ អាចឆ្លើយតបទៅ នឹងបញ្ហាប្រឈមក្នុងការការដាក់ពិដានអត្រាការប្រាក់ក្នុងឆ្នាំ២០១៧។ ទោះបីជាមិនអាចឆ្លើយតបទៅ នឹងការផ្លាស់ប្តូរថ្មីៗក៏ដោយសម្រាប់បញ្ហាប្រឈមក្នុងការបញ្ចេញ ឥណទានជាប្រាក់រៀលស្របតាមប្រកាសរបស់ធនាគារជាតិក៏ត្រូវបានដោះស្រាយតាមរយៈការជម្រុញ និងលើកទឹកចិត្តអតិថិជន ឲ្យធ្វើការប្រើប្រាស់ឥណទានជាប្រាក់រៀល។

នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្នុងបំណាច់ឆ្នាំ២០១៩ យើងនឹងសម្រេចបានគោលដៅឥណទានជាប្រាក់ រៀលចំនួន ១០%នៃសមតុល្យឥណទានសរុបស្របតាមប្រកាសរបស់ធនាគារជាតិ។ ទន្ទឹមនឹងនេះ នាងខ្ញុំ ក៏មានសុទិដ្ឋិនិយមដែរថា ឆ្នាំ២០១៩ ខេមានឹងទទួល បានជោគជ័យតាមផែនការដែលបានគ្រោងទុកព្រមទាំងដោះស្រាយបាននូវរាល់បញ្ហាប្រឈមនានា ដែលយើងជួបប្រទះក្នុងឆ្នាំ២០១៨។

តាងនាមឲ្យគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់នៃគ្រឹះស្ថាន ខេមាមីក្រូហិរញ្ញវត្ថុ លីមីធីត នាងខ្ញុំសូមថ្លែងអំណរគុណ ជូនចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់អតិថិជន ដៃគូហិរញ្ញវត្ថុ ភាគទុនិក ក្រុមប្រឹក្សាភិបាល ដែលជានិច្ចជាកាល តែងយកចិត្តទុកដាក់ និងជួយគាំទ្រដល់ ដំណើរប្រតិបត្តិការរបស់ខេមា។ នាងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះ គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ជាពិសេសបុគ្គលិកជួរមុខដែលមានឆន្ទៈ ការងារខ្ពស់ ស្មោះត្រង់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងបំពេញការងារជូនខេមាមិនខ្លាចនឿយហត់ទោះក្នុងកាលៈទេសៈណាក៏ដោយ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់

ឌិត នីតា
អគ្គនាយិកាប្រតិបត្តិ

# វិសាលភាពប្រតិបត្តិការ




| សូចនាករសំខាន់ៗ នៃផ្នែកប្រតិបត្តិការ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| រាជធានី-ខេត្តដែលកំពុងមានប្រតិបត្តិការ | ០២ | ០៣ | ០៤ | ០៤ |
| ក្រុង-ស្រុក-ខណ្ឌ ដែលកំពុងមានប្រតិបត្តិការ | ១៩ | ២២ | ២៥ | ២៨ |
| សង្កាត់-ឃុំ ដែលកំពុងមានប្រតិបត្តិការ | ៩៨ | ១២០ | ១២១ | ១៤៦ |
| ភូមិដែលកំពុងមានប្រតិបត្តិការ | ២៨៧ | ៣៦១ | ៣៤៧ | ៤៤២ |
| ចំនួនសាខាស្រុកសរុប | ០១ | ០២ | ០៣ | ០៣ |
| ចំនួនបុគ្គលិកសរុប | ៥៤ | ៧៩ | ៩៤ | ៩៥ |
| ចំនួនបុគ្គលិកជាភ្នាក់ងារឥណទាន | ២៩ | ៣៨ | ៤០ | ៤៦ |

# សមិទ្ធផលសំខាន់ៗ

| ចំនុចសំខាន់ៗ ផ្នែកប្រតិបត្តិការ | ២០១៦ | ២០១៧ | ២០១៨ | ប្រែប្រួល |
|---|---|---|---|---|
| ចំនួនបុគ្គលិក | ៧៩ | ៩៤ | ៩៤ | 0% |
| ចំនួនបុគ្គលិកផ្នែកឥណទាន | ៣៨ | ៤០ | ៤៦ | ១៥% |
| ចំនួនភូមិ | ៣៦១ | ៤០២ | ៤៣២ | ៧% |
| ចំនួនអ្នកខ្ចីសកម្ម | ១.១៥៤ | ១.២៤៧ | ១.៦៤៩ | ២៨% |
| បរិមាណឥណទាន(ដុល្លារ) | ៧.៤៣០.៦៨៦ | ៧.៧៤៦.៤១៩ | ១០.៣៣៤.៦៤៨ | ៣៣% |
| បរិមាណឥណទានឯកត្តជន | ៧.៣៣១.៥៨៨ | ៧.៦៣១.៦៩៤ | ៩.៨៩៩.៩០៩ | ៣០% |
| បរិមាណឥណទានបុគ្គលិក | ៩៩.០៩៩ | ១១៤.៧២៥ | ២៩៨.៨២១ | ១៦០% |
| បរិមាណឥណទានម៉ូតូ | - | - | ២.៦៣៥ | ១00% |
| បរិមាណឥណទានរហ័ស | - | ៩.៧៩៥ | ១០៣.៥០៦ | ១,0៥៧% |
| បរិមាណឥណទានក្រុម | - | - | ១៩.៩៨០ | ១00% |
| **ចំនុចសំខាន់ៗ ផ្នែកហិរញ្ញវត្ថុ** | | | | |
| ទ្រព្យសកម្ម | ៧.៧៨៤.៧៨៦ | ៨.១២៩.៧៥៦ | ១១.២៩៧.១៤៣ | ៣៩% |
| ទ្រព្យអកម្ម | ៥.១៨១.៨៩៤ | ៥.៥២៨.២៨៦ | ៨.៥៤៩.១១៤ | ៥៥% |
| ទ្រព្យម្ចាស់ភាគទុនិក | ២.៦០២.៨៩២ | ២.៦០១.៤៧០ | ២.៧៤៨.០២៩ | ៦% |
| មូលធនវិនិយោគ | ២.១០៣.000 | ២.១០៣.000 | ២.១០៣.000 | 0% |
| ប្រាក់ចំណេញសុទ្ធរក្សាទុក | ៤៩៩.៨៩២ | ៤៩៨.៤៧០ | ៦៤៥.០២៩ | ២៩% |
| ចំណូលការប្រាក់ | ១.៣៥៤.៩១៤ | ១.៤៤៤.១៦៩ | ១.៥៣២.៣៣៥ | ៦% |
| ចំណាយការប្រាក់ | (៣៩២.០៣២) | (៤៥០.៤៧៦) | (៤៨២.៩៦៥) | ៧% |
| ចំណូលការប្រាក់សុទ្ធ | ៩៦២.៨៨២ | ៩៩៣.៦៩៣ | ១.០៤៩.៣៧០ | ៦% |
| សំវិធានធនឥណទានស្តង់ដា ឥណទានអាក្រក់ និងសង្ស័យ | (៤៧.០២១) | (១០៨.៨២៩) | (១២៥.៣២៤) | ១៥% |
| ចំណូលការប្រាក់សុទ្ធបន្ទាប់ពី សំវិធានធនឥណទានអាក្រក់ និងសង្ស័យ | ៩១៥.៨៦១ | ៨៨៤.៨៦៤ | ៩២៤.០៤៦ | ៤% |
| ចំណូលមិនមែនការប្រាក់ | ៩២.៦៩៧ | ១៤០.២១០ | ១៨៥.៦១៥ | ៣២% |
| ចំណាយបុគ្គលិក | (៣៦៥.៦៣៣) | (៤៩១.៩១៣) | (៦០១.០៨២) | ២២% |
| ចំណាយប្រតិបត្តិការ និងផ្សេងៗ | (២២២.០៦៩) | (២៧៤.៦៥៧) | (២៦០.៦៦៨) | -៥% |
| ចំណាយលើការដករំលស់ | (៣៨.៥៨៦) | (៥១.៣៤៥) | (៤៧.៦៤៩) | -៧% |
| ចំណេញ/ខាតមុនបង់ពន្ធ | ៣៨២.២៧០ | ២០៧.១៥៩ | ២០០.២៦២ | -៣% |
| ពន្ធលើប្រាក់ចំណេញ | (៧០.៩៩៦) | (៥៨.៥៨១) | (៥៣.៧០៣) | -៨% |
| ចំណេញក្នុងឆ្នាំ | ៣១១.២៧៤ | ១៤៨.៥៧៨ | ១៤៦.៥៥៩ | -១.៤% |
| ចំណេញធៀបនឹងទ្រព្យសកម្ម | ៤,00% | ១,៨៤% | ១,៦២% | -0,២% |
| ចំណេញធៀបនឹងទ្រព្យម្ចាស់ | ១១,៩៦% | ៥,៦៧% | ៥,៥១% | -0,១% |
| ទំហំហានិភ័យឥណទាន | ១,៩៦% | ២,៧១% | ១,៩៥% | -0,៧% |
| លទ្ធភាពអាចប្រតិបត្តិការខ្លួនឯង | ៧៧,0៩% | ៥៥,៦៥% | ៥៣,២៨% | -២,៤% |

## ភាគរយអតិថិជនតាមប្រភេទអាជីវកម្ម




## ចំនួនអតិថិជនតាមបណ្តារាជធានី និងខេត្ត



# ចំនួនអតិថិជនតាមភេទ




# ចំនួនអតិថិជនតាមរយៈពេលកម្ចី



# អំពីអតិថិជន

ទស្សនៈវិស័យ និងបេសកកម្ម របស់គ្រឹះស្ថាន ខេមា គឺបានផ្តល់ឱកាសសេវាមីក្រូហិរញ្ញវត្ថុដ៏ធំទូលាយ ដល់ប្រជាកសិករ សិប្បករ និងពាណិជ្ជករ ក្នុងការកែលម្អជីវភាពរស់នៅប្រកបដោយសមត្ថភាព និរន្តរភាព និងធានាបាននូវអត្ថប្រយោជន៍ខ្ពស់ ។ ខាងក្រោមនេះ គឺជាអតិថិជនដែលទទួលបានហិរញ្ញវត្ថុពីគ្រឹះស្ថាន ខេមា ដើម្បីគាំទ្រ និងជំរុញមុខរបរ និងអាជីវកម្មរបស់គាត់ឲ្យរីកលូតលាស់ទៅមុខ។

| លោកស្រី **សុខ សំអូន** | អាជីវកម្ម ៖ ម្ចាស់ហាងបាយ<br>អាសយដ្ឋាន៖ សង្កាត់ពងទឹក ខណ្ឌដង្កោ |
|---|---|



លោកស្រី សុខ សំអូន មានអាយុ ៣០ឆ្នាំ ដើមកំណើតនៅឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល។ លោកស្រីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោក មាស សុធា ជិត១០ឆ្នាំមកហើយ និងមានបុត្រចំនួន ២នាក់ គឺកូនប្រុស ១នាក់ និងស្រី ១នាក់។ សព្វថ្ងៃជាអាជីវករបើកហាងលក់បាយ នៅភូមិវត្តស្លែង សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ លោកស្រីមានប្រសាសន៍ថា លោកស្រីបានបើកហាងលក់បាយជាង ៦ឆ្នាំមកហើយរហូលមកទល់ពេលនេះ។ ការចាប់ផ្តើមបង្កើត ហាងលក់បាយដំបូងមានការលំបាកខ្លាំង ព្រោះខ្វះមុខខ្វះក្រោយទាំង ថវិការ និងសម្ភារៈ និងលក់បាយតែ ២នាក់ប្តីប្រពន្ធប៉ុណ្ណោះ ហើយមានការគាំទ្រពីសំណាក់ អតិថិជនតិចតួចបំផុត។ ដោយការខិតខំប្រឹងប្រែងមួយរយៈកាលកន្លងមក ហាងលក់បាយរបស់លោកស្រី និងស្វាមីដែលមានឃីហោ អាហារដ្ឋានវត្តស្លែង ក៏មានអតិថិជនស្គាល់ និងគាំទ្រច្រើនបន្តិចមានចំណូលសមល្មម និងរហូតមកដល់ពេលមួយដែលលោកស្រី និងស្វាមីក៏បានពិភាក្សានិងគ្នាហើយសម្រេចចិត្តថា ត្រូវពង្រីកហាងបាយឲ្យកាន់តែធំទូលាយជាងនេះ ដើម្បីឆ្លើយ

តបទៅ នឹងកំណើនរបស់អតិថិជន ហើយក៏សម្រេចចិត្ត ទំនាក់ទំនង មកភ្នាក់ងារឥណទាន ដើម្បីសុំកម្ចីឥណទានពី គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត លើកដំបូងនៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៧ ចំនួន $៥,០០០ដោយយល់ឃើញថា គ្រឹះស្ថាន ខេមា មានបុគ្គលិករួសរាយរាក់ទាក់ និងសេវារហ័សទាន់ចិត្ត ផងនោះ។ ក្រោយពីលោកស្រី និងស្វាមីបានទទួលកម្ចីនេះហើយមានការសប្បាយចិត្តជាពន់ពេក និងជឿជាក់ យ៉ា ងមុះមុតថាសមបំណងដូចការគ្រោងទុករបស់ពួកគាត់។ លោកស្រី និងស្វាមីមានមោទនភាពខ្លាំងណាស់ដែល គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានផ្តល់ប្រាក់កម្ចីជូនពួកគាត់។ លោកស្រីបានបន្តទៀតថា បើចំណូលដូចការរំពឹងទុក នឹងកម្ចីប្រាក់ពី គ្រឹះស្ថាន ខេមា ដើម្បីពង្រីកហាងជាបន្តបន្ទាប់ និងមានផែនការ កម្ចីប្រាក់លើកទី២ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ ចំនួន $១៧,០០០ បន្ថែមទៀត ដើម្បីពង្រីកហាងបាយ និងបន្ថែមបុគ្គលិកមួយចំនួន។ ដោយឃើញមានការរីកចម្រើនជាលំដាប់ អតិថិជនគាំទ្រកាន់តែច្រើន ហើយចំណូលវិញក៏សមប្រកបគួរជាទីពេញចិត្តនោះ នៅក្រោមស្នាមញញឹមដែលមានទឹកមុខសប្បាយរីករាយ ប្តីប្រពន្ធមួយគូរនេះក៏នៅតែហាក់មិនទាន់អស់ចិត្តជាមួយការពង្រីក ហាងបាយដែលមានកន្លែងកញ្ចុះអង្គុយលេងសម្រាប់ បំពេញតម្រូវការ អតិថិជនរបស់ខ្លួន ហើយក៏នៅតែមានបំណង់កម្ចី ប្រាក់ពីគ្រឹះស្ថាន ខេមា ជាលើកទី៣ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ចំនួន $២២,០០០ ដើម្បីធ្វើកញ្ចុះអង្គុយលេង និងបន្ថែមបុគ្គលិកមួយចំនួនទៀតហើយក៏ឆក់ឱកាសគៀងគរយកអតិថិជនឲ្យបានកាន់តែច្រើនឡើងៗ និងមានប្រភពចំណូលកាន់តែខ្ពស់គួរ ជាទីមោទនភាព ស្របតាមការរំពឹងទុករបស់គ្រួសារពួកគាត់។ ជាចុងក្រោយលោកស្រី និងស្វាមីសូមថ្លែង អំណរគុណជូនចំពោះគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដែលបានផ្តល់ឱកាសឲ្យគ្រួសារពួកគាត់សាងជីវភាពបានល្អប្រសើរដែលមិនអាចកាត់ថ្លៃបាន។



## លោកស្រី **ស្មាស់ រ៉ស់**

អាជីវកម្ម ៖ សិប្បកម្ម ត្បាញអង្រឹង
អាសយដ្ឋាន៖ ស្រុកពញាឮ ខេត្តកណ្តាល



លោកស្រី ស្មាស់ រ៉ស់ មានវ័យ ៥៦ឆ្នាំ ដើមកំណើតនៅឃុំឃ្លាំងស្បែក ស្រុកពញាឮ ខេត្តកណ្តាល និងស្វាមីលោកស្រីឈ្មោះ សាស់ សារីម៉ាត់ណូ មានបុត្រចំនួន ៦នាក់ នៅក្នុងបន្ទុក ២នាក់ ជាអ្នកធ្វើសិប្បកម្ម ត្បាញអង្រឹងតូចមួយ រស់នៅភូមិ១ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ លោកស្រីមានប្រសាសន៍ថាធ្វើសិប្បកម្មត្បាញអង្រឹងជិត១០ឆ្នាំមកហើយ លោកស្រីបានឲ្យដឹងទៀតថា ក្នុងមួយថ្ងៃអាចត្បាញអង្រឹងបានពី ១៥ ទៅ ២០ អង្រឹងហើយមានតាមទំហំតូច និង ធំ និងមានតម្លៃចាប់ពី ៥,០០០៛ រហូលដល់ ៨,០០០៛ វត្ថុធាតុដើមត្រូវបានទិញមកពីផ្សារអូឫស្សី។ ហើយផលិតផលដែលបានផលិតបានត្រូវធ្វើការលក់ នៅតាមបណ្តាស្រុកខេត្តនានា តាមរ៉ឺម៉កកង់បី ដោយយល់ឃើញថា អតិថិជនមានតម្រូវការរបស់របរសំភារៈផ្សេងៗ ច្រើនទៀតលោកស្រី និងស្វាមី ក៏បានសម្រេចចិត្តប្រើប្រាស់ឥណទានជាមួយ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត តាមរយៈអតិថិជនដែលរស់នៅជិតខាងគាត់ដោយប្រើប្រាស់ប្រាក់កម្ចីចំនួន ២០.០០០.០០០៛ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២១០៨ ក្នុងគោលបំណងទិញកង់បី១ទៀត និងទិញឥវ៉ាន់គ្រឿងជ័រ ថែមលើមុខរបរថ្មីដែលជាតម្រូវការរបស់អតិថិជនគាត់។ ដោយការលក់ទាំងមុខរបរចាស់ និងមុខរបរថ្មី មានអតិថិជនទទួលទិញច្រើនឡើងៗ មិនយូរប៉ុន្មានដោយយល់ឃើញថា ការរកទទួលទានកាន់តែកាក់កប ហើយកម្ចីប្រាក់ និងសេវាកម្មរបស់គ្រឹះស្ថាន ខេមា មានភាពងាយស្រួលផងនោះ ពួកគាត់ក៏បានសម្រេចចិត្តទទួលឥណទាន ពីគ្រឹះស្ថាន ខេមា ជាលើកទី២ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ ក្នុងទឹកប្រាក់ចំនួន ២០.០០០.០០០៛ ទៀតដើម្បីដាក់ឥវ៉ាន់ឲ្យកាន់ច្រើន និងឆ្លើយតបទៅនឹងតម្រូវការអតិថិជន។ នៅលើផ្ទៃមុខដ៏សប្បាយរីករាយ និងមានស្នាមញញឹមផងនោះ ពួកគាត់នឹងរកចំណូលបានកាន់តែច្រើន និងអាចឲ្យជីវភាពគ្រួសារពួកគាត់ ប្រសើរឡើងជាលំដាប់។ ហើយពួកគាត់ក៏បានថ្លែងអំណរគុណដៃគូរអភិវឌ្ឍន៍ជីវភាពគ្រួសាររបស់ពួកគាត់ គឺគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត សូមឲ្យកាន់តែរីកចម្រើនជោគជ័យជានិរន្តរ៍។

## អ្នកស្រី **កែវ ឌីម៉ង**

អាជីវកម្ម ៖ កង់បី (PassApp)
អាសយដ្ឋាន៖ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ




លោក កែវ ឌីម៉ង់ មានអាយុ ៣៦ឆ្នាំមានដើមកំណើតនៅ ឃុំសាមគ្គី ខេត្តបាត់ដំបង លោកបានរៀបអាពាហ៍ពិពាហ៍ ជាមួយលោកស្រី ម៉េង យូដាលីន នៅឆ្នាំ ២០០៦ និងមានបុត្រ២នាក់ ស្រី១នាក់ ប្រុស ១នាក់ រស់នៅភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ដើមឡើយ លោកជាកម្មករសំណង់ម្នាក់ និងភរិយាជាកម្មការិនីកាត់ដេរ។ ដោយសារលោកកំពុងបំពេញការងារសំណង់ លោកក៏មានគ្រោះថ្នាក់បាក់ដៃម្ខាង ធ្វើឲ្យលោកធ្វើការធ្ងន់លែងបាន ក៏ត្រូវបានប្តូរមុខរបរមករត់ម៉ូតូឌុបវិញជាមួយ នឹងរបរនេះលោកខិតខំបម្រើសេវាយ៉ាងល្អជូនដល់អតិថិជនរបស់គាត់ និងមានម៉ូយគាំទ្រយ៉ាងច្រើន លោកប្រកបមុខរបរនេះអស់រយៈពេញជិត ១០ឆ្នាំមកហើយ។ លោក កែវ ឌីម៉ង់ មានប្រសាសន៍បន្តទៀតថា តាមការប្រមើលមើលរបស់លោកឃើញថាតម្រូវការអតិថិជនប្រើប្រាស់ សេវាកង់បី(PassApp) កាន់តែច្រើនឡើងៗ ជាហេតុដែលធ្វើឲ្យលោកមានបំណងចង់ផ្លាស់ប្តូរមុខរបរ មករត់កង់បីវិញ។ លោកបន្តទៀតថា លោក និងភរិយា ក៏បានពិភាក្សាគ្នាចង់ទិញកង់បី(PassApp) រត់នឹងគេ ប៉ុន្តែដោយសារមានថវិការមិនគ្រប់ចំនួនលោកក៏សម្រេចចិត្តមកទំនាក់ទំនងជាមួយបុគ្គលិករបស់ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ចង់បានកម្ចីឥណទានយានយន្ត ដើម្បីបង្គ្រប់ទិញកង់បី (PassApp) ដោយសារលោកមានទុនចូលរួមខ្លះ លោក និងភរិយា ក៏សម្រេចចិត្តថាស្នើសុំកម្ចីឥណទានពី គ្រឹះស្ថាន ខេមា ចំនួន $២,៨០០ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០១៨ ក្រោយពីបានទទួលកម្ចីយកទៅទិញកង់បី (PassApp)សមតាមបំណងប្រាថ្នាលោកនិងភរិយា មានចិត្តសប្បាយរីករាយ ជាពន់ពេក ហើយក៏សូមអរគុណចំពោះ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដែលមានទំនុកចិត្ត និងផ្តល់ឱកាសឲ្យគ្រួសាររបស់ពួកគាត់។ ពួកគាត់បានបន្តទៀតថាមុខរបរត់កង់បី (PassApp) នេះធ្វើឲ្យក្រុមរបស់គ្រួសារគាត់រកចំណូលបន្ថែមបានយ៉ាងល្អប្រសើរជាងពីមុន។ ជាថ្មីម្តងទៀតលោក កែវ ឌីម៉ង់ និង លោកស្រីម៉េង យូដាលីន ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត សារជាថ្មីក្នុងការសម្រេចនូវគោលបំណង និងសាងជីវភាពរបស់ក្រុមគ្រួសារពួកគាត់ឲ្យរកប្រាក់ចំណូលបានគាប់ប្រសើរជាងពីមុន។



**លោកស្រី ឱត នីតា**
អគ្គនាយិកាប្រតិបត្តិ

លោកស្រី **ឱត នីតា** បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មនៅក្នុងឆ្នាំ ២០០៣ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងឆ្នាំ២០០៥នៅសកលវិទ្យាល័យជាតិអូស្ត្រាលី (Australian National University) ។ លោកស្រី មានបទពិសោធន៍ក្នុងការគ្រប់គ្រងអាជីវកម្ម និងគ្រប់គ្រង ឥណទាន ចាប់តាំងពីឆ្នាំ២០០៨។ មុនការបង្កើតឡើងនូវ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត លោកស្រីជាម្ចាស់ និងជាអ្នកគ្រប់គ្រងក្រុមហ៊ុនសំណង់។ ក្នុងពេលជាមួយគ្នានេះដែរ លោកស្រីបានធ្វើជា ប្រតិបត្តិករឥណទានឯកជន និងបានចុះបញ្ជីជាផ្លូវការជាមួយ ធនាគារជាតិ នៃកម្ពុជាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាប់តាំងពីឆ្នាំ២០១០។ លោកស្រី ឱត នីតា គឺជាស្ថាបនិក និងជាអគ្គនាយិកាប្រតិបត្តិ នៃគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុលីមីតធីត។



**លោក ឱត វណ្ណារិទ្ធ**
នាយក នាយកដ្ឋានព័ត៌មានវិទ្យា

លោក **ឱត វណ្ណារិទ្ធ** បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៨ ហើយលោកផ្ទាល់ក៏មានជំនាញផ្នែកព័ត៌មានវិទ្យា លើកម្មវិធីVB6, VB.Net និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យម៉ាស៊ីនបម្រើ SQL។ លោកមានបទពិសោធន៍១៧ឆ្នាំ ក្នុងវិស័យធនាគារ រួមមាន ៖ ព័ត៌មានវិទ្យា គណនេយ្យ និងហិរញ្ញវត្ថុរតនាគារ។ លោកធ្លាប់បានបម្រើការងារជាមួយ នឹងធនាគារអេស៊ីលីដា ភីអិលស៊ី ច្រើនជាង១៣ឆ្នាំលើតួនាទីជាគណនេយ្យករ ប្រធានផ្នែកបេឡាករ និងគណនេយ្យករ មុនពេលចូលរួម ជាមួយនឹងគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។ បច្ចុប្បន្ននេះ លោកមានតួនាទីជា នាយកនាយកដ្ឋានព័ត៌មានវិទ្យា នៃគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។



**លោកស្រី អ៊ុក ស៊ុនធារី**
នាយិកា នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

លោកស្រី **អ៊ុក ស៊ុនធារី** បានបញ្ចប់បរិញ្ញាប័ត្រផ្នែក គណនេយ្យក្នុងឆ្នាំ២០០១និង អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ក្នុង ឆ្នាំ ២០០៤ នៅវិទ្យាស្ថានជាតិគ្រប់គ្រង។ លោកស្រីមានបទពិសោធន៍ការងារ គណនេយ្យ ហិរញ្ញវត្ថុ និងគ្រប់គ្រងផែនការថវិការអាជីវកម្មច្រើនជាង ១៧ឆ្នាំជាមួយ និង ស្ថាប័នមួយចំនួនមានដូចជាៈ ធនាគារមកពីក្រៅស្រុក ស្ថាប័នរដ្ឋ ក្រោមកិច្ចសហប្រតិបត្តិការអង្គការសហប្រជាជាតិ និងក្រុមហ៊ុនឯកជន។ លោកស្រីក៏បានចូលបម្រើការងារគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុនៅក្នុងខែ ធ្នូ ឆ្នាំ ២០១៦ ក្នុងតួនាទីជានាយិការង នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបានតំឡើងតួនាទីជា នាយិកា នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៅក្នុងខែ មិថុនា ឆ្នាំ ២០១៨ រហូតមកដល់បច្ចុប្បន្ន។



**លោក យ៉ាំង ហៃ**
នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក **យ៉ាំង ហៃ** បានបញ្ចប់បរិញ្ញាបត្រ ជាន់ខ្ពស់លើ មុខជំនាញហិរញ្ញវត្ថុ និងធនាគារ ក្នុងឆ្នាំ ២០១០ និង សញ្ញាបត្របរិញ្ញាបត្រជំនាញ គណនេយ្យ និងហិរញ្ញវត្ថុ នៅវិទ្យាស្ថានជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៣។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនមានដូចជាប្រសិទ្ធភាព នៃការត្រួតពិនិត្យផ្ទៃក្នុងសវនកម្មផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យឥណទានកម្រិតខ្ពស់ ជំនាញក្នុងការដឹកនាំការសរសេររបាយការណ៍ច្បាប់ពន្ធរបស់កម្ពុជាជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងការក្លែងបន្លំ។ លោកក៏ធ្លាប់បម្រើការងារនៅគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុប្រាសាក់ និង អិលអូអិលស៊ី ច្រើនជាង ១០ឆ្នាំ ក្នុងតួនាទីជាភ្នាក់ងារសវនករផ្ទៃក្នុង សវនករផ្ទៃក្នុងជាន់ខ្ពស់ ហើយក៏ជាប្រធានផ្នែកសវនករប្រតិបត្តិការ។ បច្ចុប្បន្ននេះលោកមានតួនាទី ជានាយក នាយកដ្ឋាន សវនកម្មផ្ទៃក្នុងនៃគ្រឹះស្ថានខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។



**លោក លី ឈាង**
នាយក នាយកដ្ឋានឥណទាន

លោក **លី ឈាង** បានបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៩។ លោកមានបទពិសោធន៍ ច្រើនជាង១០ឆ្នាំ នៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ លោកធ្លាប់បានកាន់តំណែងជាច្រើននៅធនាគារក្នុងនោះជាភ្នាក់ងារឥណទានខ្នាតតូចបំផុត ឥណទានខ្នាតតូច ឥណទានខ្នាតមធ្យម ឥណទានគេហដ្ឋាន អនុប្រធានភ្នាក់ងារឥណទាន និងជាប្រធានភ្នាក់ងារឥណទានសាខា ។

លោកចូលបម្រើការងារជាមួយ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត នៅក្នុងមុខតំណែងជានាយក ការិយាល័យប្រតិបត្តិការ នៅឆ្នាំ២០១៥ និងបន្ទាប់មកត្រូវ បានដំឡើងមុខងារទៅជា នាយក នាយកដ្ឋានឥណទាន ចាប់តាំងពីខែមីនា ឆ្នាំ២០១៦ រហូតដល់ពេលបច្ចុប្បន្ន។



**លោក មុំ ចាន់សុធា**
នាយក នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស

លោកបានចូលបម្រើការងារនៅ ខេមា ក្នុងឆ្នាំ២០១៦។ លោក **មុំ ចាន់សុធា** មានបទពិសោធន៍ជិត ១០ឆ្នាំ លើការគ្រប់គ្រងកិច្ចការរដ្ឋបាល និងធនធានមនុស្ស និងហិរញ្ញវត្ថុ និងគ្រប់គ្រងស្ថាប័ន ជាមួយនឹងអង្គការជាតិ អន្តរជាតិ និងស្ថាប័ន មីក្រូហិរញ្ញវត្ថុមួយចំនួន។ លើសពីនេះទៀតលោកក៏ធ្លាប់ជា សមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការប្រតិបត្តិករឥណទាន។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រកសិកម្ម បរិញ្ញាបត្រផ្នែកអប់រំ លើជំនាញភាសាអង់គ្លេស នៅសាកលវិទ្យាល័យធនធានមនុស្ស និងសញ្ញាបត្រគ្រូបច្ចេកទេសជាន់ខ្ពស់ នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសក្នុងឆ្នាំ ២០០៧។

បច្ចុប្បន្ននេះ លោកមានមុខដំណែងជា នាយក នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។



**លោក ហែម គោសល្យ**
នាយក ការិយាល័យប្រតិបត្តិការ

លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន ខេមា តាំងពីឆ្នាំ២០១៦ដល់បច្ចុប្បន្ន។ លោក **ហែម គោសល្យ** មានបទពិសោធន៍ ៩ឆ្នាំ ក្នុងផ្នែកទីផ្សារ និងផ្នែកគ្រប់គ្រងស្ថាប័នឯកជន និងគ្រឹះស្ថានធនាគារមួយចំនួនដូចជា ៖ ធនាគារម៉ារូហាន់ ធនាគារវឌ្ឍនៈ និងធនាគារឯកទេសខ្មែរ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មជំនាញហិរញ្ញវត្ថុ នៅសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាក្នុងឆ្នាំ២០១២ និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ ផ្នែកគណិតវិទ្យា នៅសកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៤។ បច្ចុប្បន្ននេះលោកមានតួនាទីជា នាយក ការិយាល័យ ប្រតិបត្តិការ នៃគ្រឹះស្ថានខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។



**លោក ចាប រ័ត្នមុនី**
នាយក សាខាអង្គស្នួល

លោក **ចាប រ័ត្នមុនី** បានចូលបម្រើការងារនៅ ខេមា ក្នុងឆ្នាំ២០១២ ក្នុងមុខតំណែងជាភ្នាក់ងារឥណទាន និងត្រូវបានតែងតាំង ជាប្រធានក្រុមភ្នាក់ងារឥណទានក្នុងឆ្នាំ២០១៦។ មុនពេលចូលបម្រើការងារជាមួយខេមាលោកបានបម្រើការងារគ្រឹះស្ថានឯកជន និងមីក្រូហិរញ្ញវត្ថុក្នុងវិស័យឥណទានជាច្រើន។ លោកមានបទពិសោធន៍ ៨ឆ្នាំ លើការអប់រំផ្នែកទីផ្សារ និងឥណទាន។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រ គីមីជីវៈ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៧។ នៅដើមឆ្នាំ២០១៧លោកត្រូវបានដំឡើងតំណែងមុខងារជា នាយកសាខា អង្គស្នួល រហូតដល់បច្ចុប្បន្ន។



**លោក សេខ ចំណាច់**
នាយក សាខាក្រុងតាខ្មៅ

លោកបានបម្រើការងារនៅ ខេមា ក្នុងមុខតំណែងជានាយកសាខាអង្គស្នួលក្នុងឆ្នាំ២០១៦ ដោយបានផ្លាស់ប្តូរមកកាន់ជានាយក សាខាក្រុងតាខ្មៅវិញក្នុងឆ្នាំ២០១៧។ ដោយលោក **សេខ ចំណាច់** មានបទពិសោធន៍ ១១ឆ្នាំ លើផ្នែកឥណទាន និងគ្រប់គ្រង ក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខេម ខេបភីថល ភីអិលស៊ី និង ធនាគារភូមិ ខេមបូឌា អិលធីឌី (LOLC) ក្នុងមុខតំណែងជានាយកសាខាក្នុងឆ្នាំ២០១៤។ លោកបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មជំនាញ គ្រប់គ្រង នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០១៧ និងបរិញ្ញាបត្រផ្នែក គ្រប់គ្រង នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប ក្នុងឆ្នាំ២០១១។ លើសពីនេះទៀតលោកក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល មួយចំនួនលើជំនាញការពង្រឹងសមត្ថភាពបុគ្គលិកផ្នែកទីផ្សារ និងការលើកទឹកចិត្តផងដែរ។ នាពេលបច្ចុប្បន្ន លោកជានាយក សាខាក្រុងតាខ្មៅ។



**លោកស្រី នុត សិលា**
**ប្រធានផ្នែករតនាគារ**

ទទួលខុសត្រូវចំពោះ ប្រតិបត្តិការសេដ្ឋកិច្ចប្រចាំថ្ងៃរបស់ គ្រឹះស្ថាន ខេមា ទាំងមូល ដែលរួមមានដូចជាការបង្កើត និង អនុវត្តន៍គោលការណ៍រតនាគារស្រប តាមស្តង់ដារគណនេយ្យអន្តរជាតិ និង សវនកម្មឯករាជ្យធានាតម្លាភាព និងភាព ត្រឹមត្រូវនៃការគ្រប់គ្រងសាច់ប្រាក់ប្រចាំ ថ្ងៃរបស់ ការិយាល័យកណ្តាល និងសាខា ចាត់ចែង និងរៀបចំរបាយការណ៍លំហូរ សាច់ប្រាក់អោយមានប្រសិទ្ធភាព និង ទាន់ពេលវេលា គ្រប់គ្រងប្រតិបត្តិការ និងព័ត៌មានពាក់ព័ន្ធ ជាមួយវិស័យធនាគារ ភ្នាក់ងារផ្ទេរប្រាក់ ភ្នាក់ងារប្តូរប្រាក់ និង ម្ចាស់បំណុល។ លើសពីនេះប្រធានផ្នែក រតនាគារមាន តួនាទីវិភាគ និងកំណត់ ឱកាសក្នុងការវិនិយោគ ដើម្បីបង្កើនប្រាក់ ចំណូល និងកាត់បន្ថយការចំណាយផ្សេង របស់គ្រឹះស្ថាន។ ប្រធានផ្នែក រតនាគារ ក៏ទទួលបន្ទុកចូលរួមក្នុងដំណើរការជ្រើស រើសបុគ្គលិកមានជំនាញព្រមទាំងបង្កើត មេរៀនសម្រាប់បណ្តុះបណ្តាល បុគ្គលិក ដែលពាក់ព័ន្ធ ក្នុងគោលដៅពង្រឹង និង អភិវឌ្ឍន៍សមត្ថភាពបុគ្គលិកអោយ បាន ល្អប្រសើរ។



**កញ្ញា ខុន្ធី វ៉ាន់**
**ប្រធានផ្នែកហិរញ្ញវត្ថុ**

ទទួលខុសត្រូវចំពោះប្រតិបត្តិការ គណនេយ្យទូទៅ របស់ គ្រឹះស្ថាន ខេមា ទាំងមូល ដែលរួមមានដូចជាការបង្កើត និងអនុវត្តន៍គោលការណ៍ គណនេយ្យ ស្រប តា មស្តង់ដារគណនេយ្យអន្តរជាតិ និងសវនកម្មឯករាជ្យធានាតម្លាភាព និង ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយាល័យ កណ្តាលនិងសាខា ក៏ ដូ ចជាស្ថាប័នដែលពាក់ ព័ន្ធដឹកនាំការ ធ្វើតេស្ត និងបង្កើតលេខកូដគណនីទៅ លើផ លិ តផលឥណទាន និងទម្រង់គំ ថ្មីៗនៅក្នុងប្រព័ន្ធ និង ត្រួតពិនិត្យសកម្ម ភាពអនុវត្តន៍ប្រតិបត្តិការសេដ្ឋកិច្ចប្រចាំ ថ្ងៃនៅក្នុងប្រព័ន្ធ ផ្តល់ការគាំទ្រ និងអំពី អនុសាសន៍ពាក់ព័ន្ធ និងការងារបច្ចេក ទេសទៅនាយកដ្ឋានពាក់ព័ន្ធ និងគ្រប់ ការិយាល័យសាខា។ ក្រៅពីនេះប្រធាន ផ្នែកគណនេយ្យក៏ទទួលបន្ទុកចូលរួមក្នុង ដំណើរការជ្រើសរើស បុគ្គលិកជំនាញ ព្រមទាំងបង្កើតមេរៀនសម្រាប់ បណ្តុះ បណ្តាលបុគ្គលិកដែលពាក់ព័ន្ធក្នុងគោល ដៅពង្រឹង និងអភិវឌ្ឍន៍សមត្ថភាពរបស់ បុគ្គលិកអោយបាន ល្អប្រសើរ។



**លោក ញៀប ដាលាត**
**ប្រធានផ្នែកព័ត៌មានវិទ្យា**

ចូលរួមធ្វើបច្ចុប្បន្នកម្ម ទៅលើ គោលការណ៍ និងនីតិវិធីផ្សេងៗ ក្នុង នាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មានហើយធានា ថាគោលការណ៍ និងនីតិវិធីទាំងនោះមាន លក្ខណៈគ្រប់ជ្រុងជ្រោយ និងឆ្លើយតប ទៅនឹង ការរកឃើញរបស់សវនករឯករាជ្យ ។ ចូលរួមដោះស្រាយរាល់បញ្ហាស្តីអំពី ប្រព័ន្ធព័ត៌មានវិទ្យាដែលលើកឡើងដោយ សវនករឯករាជ្យ សវនករផ្ទៃក្នុង ការិយា ល័យឥណទានកម្ពុជា (CBC) និងបុគ្គលិក អ្នកប្រើប្រាស់ផ្ទាល់ក្នុង គ្រឹះស្ថាន ខេមា។ សហការជាមួយក្រុមការងារ Morakot ដើម្បីធ្វើបច្ចុប្បន្នកម្មលើប្រព័ន្ធ Morakot ទៅតាមតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថាន ។ ហ្វឹកហ្វឺន ចាត់ចែង ត្រួតពិនិត្យ និង វាយតម្លៃលើការងារប្រចាំថ្ងៃរបស់បុគ្គលិក បច្ចេកវិជ្ជាព័ត៌មាន។បំពេញការងារផ្សេងៗ ដែលនាយកនាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មាន ឬអគ្គនាយិកាប្រតិបត្តិដាក់ជូន ។

# រចនាសម្ព័ន្ធគ្រប់គ្រង



# ផលិតផល និងសេវាកម្ម

ផលិតផលរបស់ខេមា គឺជាឥណទាន។ ឥណទាននេះត្រូវបានផ្តល់ជូនទៅអតិថិជនសម្រាប់ប្រើប្រាស់ទូទៅដូចជាៈទិញរបស់របរប្រើប្រាស់ ឬមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬ ធ្វើអាជីវកម្មខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ។ ក្នុងការផ្តល់សេវាកម្ម ខេមា បានកំណត់នូវបទដ្ឋានការបម្រើជូនអតិថិជនដូចខាងក្រោមៈ

- ផ្តល់ឥណទានលឿននិងមានប្រសិទ្ធភាព។សម្រាប់អតិថិជនថ្មីឥណទានត្រូវបានផ្តល់ជូនក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរ ក្នុងករណីអតិថិជនផ្តល់ឯកសារគ្រប់គ្រាន់។ សម្រាប់អតិថិជនចាស់ដែលធ្លាប់ប្រើប្រាស់ឥណទានរបស់ខេមា ឥណទានត្រូវបានផ្តល់ជូនក្នុងរយៈពេល០២ថ្ងៃ។
- សេវាដល់គោលដៅ ៖ ភ្នាក់ងារឥណទានរបស់គ្រឹះស្ថាន និងបម្រើសេវាជូនអតិថិជនដល់ទីកន្លែងរបស់ពួកគាត់។
- ការត្រួតពិនិត្យសេវាអតិថិជន ៖ ផ្នែកទីផ្សាររបស់ ខេមា នឹងធ្វើការស្រាវជ្រាវ និងសម្ភាសន៍អតិថិជនពី សេវារបស់គ្រឹះស្ថាន។ ការតវ៉ា ឬ ការផ្តល់យោបល់ផ្សេងៗ ពីសំណាក់អតិថិជនត្រូវបានកត់ត្រាទុក និងរាយការណ៍ជូនថ្នាក់ដឹកនាំ និងយកមកកែតម្រូវដើម្បីឲ្យការផ្តល់សេវាកាន់តែល្អប្រសើរ។

## ឥណទានក្រុមធានា

ឥ ណទា នក្រុមធានា ត្រូវបានផ្តល់ជូនអតិថិជនជាប្រាក់រៀល ដែលមានកម្រិតជីវភាពទាប ឬទាបបំ ផុតហើយមានមុខរបរចិញ្ចឹមជីវិតជា លក្ខណៈកសិកម្មដូចជា ៖ ធ្វើស្រែ ចម្ការ ចិញ្ចឹមសត្វ និងជំនួញតូចតាចដែលទាក់ទងនឹង វិស័យកសិកម្ម។ ឥណទាននេះតម្រូវឲ្យប្រជាជនឬ អតិថិជនប្រមូលផ្តុំជាក្រុមដែល មានមេក្រុមម្នាក់ និងសមាជិកចាប់ពី ០២នាក់ដល់ ០៥នាក់។ ទំហំឥណទានក្រុមផ្តល់ជូនរហូតដល់ ២.០០០.០០០៛ សម្រាប់សមាជិកម្នាក់រយៈពេល ខ្ចី២៤ខែ អត្រាការប្រាក់ ១៨% ក្នុងមួយឆ្នាំ របៀបសង ៖ រំលស់ប្រាក់ដើមបូកការប្រាក់រៀងរាល់ខែ។

## ឥណទានយានយន្ត

ខេមាផ្តោត សំខាន់លើរូបវន្តបុគ្គល ដែលមានចំណូលទៀងទាត់ មានទំនុកចិត និងមានតម្រូវការទិញម៉ូតូ ឬម៉ូតូកង់បី យកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រកបអាជីវកម្មស្របទៅនឹងច្បាប់រួមមានៈ បុគ្គលិកក្រុមហ៊ុន អង្គការ មន្ត្រីរាជការ អាជីវករឬអតិថិជនផ្សេងទៀត។ល។ អត្រាការប្រាក់ប្រចាំឆ្នាំគឺ ១៨% ក្នុង ១ឆ្នាំ សម្រាប់ទំហំឥណទានយានយន្តសម្រាប់ទិញម៉ូតូរហូតដល់ USD ២.០០០ ឬ ៨លានរៀល និងឥណទានយានយន្តសម្រាប់ទិញម៉ូតូកង់បី USD ៣.០០០ ឬ ១២លានរៀល ហើយមានរយៈពេលខ្ចីរហូតដល់ ៣៦ខែ ជាមួយនឹងរបៀបសង ៖ រំលស់ប្រាក់ដើមបូកការប្រាក់ថេររៀងរាល់ខែដោយអតិថិជនអាចជ្រើសរើសថ្ងៃសងប្រាក់ទីមួយបានតាមតម្រូវការ ។

## ឥណទានខ្នាតតូចបំផុត

ឥណទានខ្នាតតូចបំផុត ត្រូវបានផ្តល់ជូនសម្រាប់បម្រើតម្រូវការទីផ្សារ ទៅតាមកម្រិតទំហំអាជីវកម្មរបស់ពលរដ្ឋ នៅតាមទីជនបទ ប្រជុំជនទីក្រុង និងតំបន់នានាទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឥណទានខ្នាតតូចបំផុត ផ្តល់ជូនជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល ទំហំឥណទាន រហូតដល់ USD ៤.០០០ ឬសមមូលប្រាក់រៀល រយៈពេលខ្ចីរហូតដល់៣៦ខែជាមួយអត្រាការប្រាក់១៨%ក្នុងមួយឆ្នាំរបៀបសង ៖ រំលស់ប្រាក់ដើមបូកការប្រាក់រៀងរាល់ខែ និងរំលស់ប្រាក់ដើមបូកការប្រាក់ថេររៀងរាល់ខែ ។

## ឥណទានខ្នាតតូច

ឥណទានខ្នាតតូចបង្កើតឡើង គឺដើម្បីផ្តល់មូលនិធិដល់អ្នកខ្ចី ក្នុងការផ្គត់ផ្គង់តម្រូវការប្រើប្រាស់គ្រប់ប្រភេទអាជីវកម្មរួមមាន ៖ ផលិតកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម និង ទេសចរណ៍ ដើម្បីឲ្យអាជីវករមានលទ្ធភាពបង្កើនប្រាក់ចំណូលរបស់ខ្លួន។
ឥណទានខ្នាតតូចផ្តល់ជូនជាប្រាក់ ដុល្លារអាមេរិក និងប្រាក់រៀល ទំហំឥណទានចាប់ពីUSD ៤,០០១ រហូតដល់ USD ១០.០០០ ឬសមមូលប្រាក់រៀល រយៈពេលខ្ចីរហូតដល់៦០ខែជាមួយអត្រាការប្រាក់ ១៨% ក្នុងមួយឆ្នាំ របៀបសង ៖ រំលស់ប្រាក់ដើមបូកការប្រាក់រៀងរាល់ខែ និង រំលស់ប្រាក់ដើមបូកការប្រាក់ថេររៀងរាល់ខែ ។

## ឥណទានខ្នាតមធ្យម

ឥណទានខ្នាតមធ្យមបង្កើតឡើង គឺដើម្បីផ្តល់មូលនិធិ ដល់អ្នកខ្ចី ក្នុងការផ្គត់ផ្គង់តម្រូវការប្រើប្រាស់ទៅលើ សហគ្រាសធនតូច និងមធ្យមអាជីវកម្មគ្រប់ប្រភេទរួមមាន ៖ ផលិតកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម និង ទេសចរណ៍ដែលមានមុខរបរការងារច្បាស់លាស់ និងស្របតាមច្បាប់មានកេរ្តិ៍ឈ្មោះ និងទំនាក់ទំនងល្អក្នុងសង្គម។ឥណទានខ្នាតមធ្យមផ្តល់ជូន ជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល ទំហំឥណទានចាប់ពីUSD ១០.០០១ រហូតដល់ USD ២០០.០០០ ឬ សមមូលប្រាក់រៀល រយៈពេលខ្ចីរហូតដល់៦០ខែ ជាមួយអត្រាការប្រាក់ចាប់ពី ១៥,៦% ទៅ ១៨%ក្នុងមួយឆ្នាំ របៀបសង ៖ រំលស់ប្រាក់ដើមបូកការប្រាក់រៀងរាល់ខែ និង រំលស់ប្រាក់ដើមបូកការប្រាក់ថេររៀងរាល់ខែ។

## ឥណទានរហ័ស

ខេមា ផ្តល់ឥណទានជូនដល់អតិថិជនទាំងឡាយណា ដែលជារូបវន្តបុគ្គលដែលប្រកបមុខរបរក្នុងវិស័យដូចជា ៖ កសិកម្ម ពាណិជ្ជកម្ម សេវាកម្ម សិប្បកម្មឧស្សាហកម្មគ្រួសារ ។ល។អត្រាការប្រាក់ប្រចាំឆ្នាំគឺ១៨%ក្នុង ១ឆ្នាំ ជាមួយនឹងទំហំឥណទានរហូតដល់ USD ១.០០០ ឬ សមមូលជាប្រាក់រៀល ហើយមានរយៈពេលខ្ចីរហូតដល់ ១៨ខែ ជាមួយនឹងរបៀបសង ៖ រំលស់ប្រាក់ដើមបូកការប្រាក់រៀងរាល់ខែ និងរំលស់ប្រាក់ដើមបូកការប្រាក់ថេររៀងរាល់ខែ។

## ឥណទានបុគ្គលិក

ខេមា ផ្តល់ឥណទានដល់បុគ្គលិកដើម្បីជួយសម្រួលបុគ្គលិកក្នុងការបំពេញកង្វះខាតក្នុង ការទិញអ្វីដែលចាំបាច់ និងផ្គត់ផ្គង់ការខ្វះខាតផ្សេងៗ ក្នុងជីវភាពប្រចាំថ្ងៃ។ ទំហំឥណទាន (ដោយគណនាផ្អែកទៅតាមលទ្ធផលភាពសងរបស់បុគ្គលិក) ៤០%ទៅ ៨០% នៃប្រាក់បៀវត្សសុទ្ធបូកជាមួយប្រាក់ជួលឧបករណ៍សម្ភារៈផ្សេងៗ ជាមួយ ខេមា។ មានរយៈពេលខ្ចីរហូតដល់៦០ខែជាមួយអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី ១៣,២% ដល់ ១៥.៦%។

# សង្ខេបសកម្មភាពទីផ្សារ

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានចាប់កំណើតចេញពីការផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធ ឬអាចនិយាយបានថា "ប្រាក់កម្ចីចងការជាលក្ខណៈគ្រួសារ" មិនមានភាពពេញលេញទៅតាមផ្លូវច្បាប់នៅឡើយទេនៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង។ ដោយមានការកើនឡើងនូវចំនួនអតិថិជន និងតម្រូវការប្រាក់កម្ចីកាន់តែច្រើនឡើងៗ និងដើម្បីការពារបាននូវប្រយោជន៍របស់អតិថិជននិងការពង្រីកខ្លួនឲ្យបានកាន់តែធំ សមស្របទៅតាមស្ថានភាពទីផ្សារកំពុងអភិវឌ្ឍន៍ជាក់ស្តែង ដែលអាចលក់ផលិតផលច្រើនសំបូរបែប នៅលើទីផ្សារ និងសម្រេចបាននូវផែនការជាយុទ្ធសាស្ត្ររបស់ខ្លួនផងនោះ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានស្នើសុំធ្វីប្រតិបត្តិការជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ពេញលេញ ដោយបានប្រសូត្រចេញជារូបរាងយ៉ាងពិតប្រាកដ ដោយទទួលបានអជ្ញាប័ណ្ណជាផ្លូវការពី ធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១០ ។

អតិថិជន ស្គាល់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត កាន់តែច្បាស់តាមរយៈសកម្មភាព ចុះធ្វើប្រតិបត្តិការផ្តល់ឥណទាន ដល់ទីកន្លែងទាំងតំបន់ទីប្រជុំជន និងតំបន់ជាយៗ រាជធានីភ្នំពេញ និងបណ្តាស្រុកនានានៃទីរួមខេត្តកណ្តាល ដោយមានការគាំទ្រយ៉ាងពេញទំហឹង ពីអជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់នៅក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន ដែលកាន់តែមានភាពងាយស្រួលដល់ ដំណើរការនៃការផ្សព្វផ្សាយនូវផលិតផល និងសេវាកម្មរបស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត។ ក្នុងនោះដែរអតិថិជនដែលបានប្រើប្រាស់នូវផលិតផល សេវាកម្ម ជាមួយ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ អំពីផលិតផលរបស់យើង ពីអតិថិជនដែលមិនធ្លាប់ស្គាល់មកស្គាល់គ្រឹះស្ថាន និងបានមកប្រើប្រាស់ជាបន្តបន្ទាប់មិនដាច់ ។ យើងក៏បានរៀបចំឡើងនូវការផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយផ្សេងៗ ដើម្បីធានាថាព័ត៌មាន និងសារផ្សព្វផ្សាយទាំងអស់នោះ បានជ្រួតជ្រាបទៅដល់ទីផ្សារគោលដៅ ប្រកបទៅដោយប្រសិទ្ធភាព។ គ្រឹះស្ថានខេមា ក៏បានផ្សព្វផ្សាយជាសាធារណៈតាមរយៈការចុះផ្សព្វផ្សាយ ផ្ទាល់នៅការិយាល័យកណ្តាល និងការិយាល័យសាខាផងដែរ។ ហើយសកម្មភាពនៃការចុះផ្សព្វផ្សាយ និងលក់ដោយផ្ទាល់ទាំងនោះក៏បានអនុវត្តស្របពេលជាមួយ នឹងការផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយនានាផងដែរ។ សវនករផ្ទៃក្នុង និងផ្នែកត្រួតពិនិត្យឥណទាននៃការិយាល័យកណ្តាល និងការិយាល័យសាខាតែងតែចុះសាកសួរ អំពីគុណភាពនៃការបម្រើក្រមសីលធម៌របស់បុគ្គលិកដើម្បីបង្កើនទំនាក់ទំនងល្អជាមួយ អតិថិជនតាមដានការវិវត្តអាជីវកម្មរបស់អតិថិជន ព្រមទាំងផ្តល់នូវដំណោះស្រាយផ្នែកហិរញ្ញវត្ថុផ្សេងៗផងដែរ។ បុគ្គលិកទាំងអស់ជាពិសេសបុគ្គលិកជួរមុខត្រូវបានទទួលការ បណ្តុះបណ្តាលជាប្រចាំអំពីបច្ចេកទេសជំនាញ និងការបម្រើសេវាអតិថិជនល្អឥតខ្ចោះជូនចំពោះអតិថិជន។ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដែលអតិថិជនជឿទុកចិត្ត និងទទួលបានការគាំទ្រដោយគ្រឹះស្ថានប្រកាន់ភ្ជាប់នូវគុណតម្លៃទាំង០៤គឺ ៖

- សេវាកម្ម ឆាប់រហ័ស ៖ ផ្តល់នូវសេវាកម្ម ដ៏ល្អបំផុតប្រកបដោយ សមភាព ប្រសិទ្ធភាព និងរហ័សទាន់ចិត្ត ជូនអតិថិជន ។
- ភាពស្មោះត្រង់ ៖ ភាពស្មោះត្រង់របស់បុគ្គលិកគ្រប់លំដាប់ថ្នាក់ ក្នុងការផ្តល់សេវាកម្ម និងផលិតផល ហិរញ្ញវត្ថុ ជូនអតិថិជនទាំងអតិថិជនខាងក្នុងនិងអតិថិជនខាងក្រៅ ប្រកបទៅដោយសីលធម៌វិជ្ជាជីវៈ ។

តម្លាភាព ៖ ផ្តល់ព័ត៌មានលម្អិតអំពីផលិតផត និង
- សេវាកម្ម ជូនអតិថិជន ឲ្យបានច្បាស់លាស់ និង គ្រប់ជ្រុងជ្រោយ ដើម្បីឲ្យអតិថិជន បានយល់ ច្បាស់អំពីផលិតផល និងសេវាកម្មរបស់គ្រឹះស្ថាន

ការគោរព ៖ បុគ្គលិកគ្រប់លំដាប់ថ្នាក់ ប្រកាន់
- ភ្ជាប់នូវភាពថ្លៃថ្នូរ រួសរាយរាក់ទាក់ គោរពគ្នាទៅវិញទៅមក គោរពអតិថិជន និងយល់ពីស្ថានភាពរបស់អតិថិជន ។



# ការកសាងសមត្ថភាពបុគ្គលិក



## ការលើកទឹកចិត្តបុគ្គលិកលើសមិទ្ធផល

ក្នុងឆ្នាំ២០១៨ នេះគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុលីមីតធីត នៅបន្តអភិវឌ្ឍន៍កែលម្អ និងផ្តល់អត្ថប្រយោជន៍បន្ថែមទៀត ដើម្បីឆ្លើយតបនឹងការខិតខំប្រឹងប្រែងឲ្យទទួលបានសមិទ្ធផលជាវិជ្ជមាន និងស្ថេរភាពកំណើនរបស់គ្រឹះស្ថាន។ ដូច្នេះគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុលីមីតធីត បានបន្តធ្វើបច្ចុប្បន្នកម្មលើការគណនាអត្ថប្រយោជន៍បុគ្គលិក ដោយផ្តោតសំខាន់ដល់បុគ្គលិកជួរមុខដែលមានការទូទាត់សំណងកំពុងត្រូវបានភ្ជាប់ទៅតាមតួនាទី និងរយៈពេលបំពេញការងារជាមួយ ខេមា ដែលទាក់ទងទៅនឹងអត្ថប្រយោជន៍ផ្សេងទៀត ដែលពួកគេអាចមានសិទ្ធិទទួលបាន។

ការធ្វើបច្ចុប្បន្នភាពលើការគណនាសំណង និងអត្ថប្រយោជន៍ថ្មីបន្ថែមទៀតនេះត្រូវបានបង្កើតឡើង គឺដើម្បីលើកទឹកចិត្តដល់គណៈគ្រប់គ្រង និងបុគ្គលិករបស់យើង។ គោលបំណងរបស់យើង គឺដើម្បីលើកទឹកចិត្តដល់បុគ្គលិកក្នុងការរក្សា និងបង្កើនការរីកចម្រើនជាវិជ្ជមានរបស់ ខេមា ទាំងលើផ្នែកប្រតិបត្តិការ និងសមិទ្ធផលការងារសង្គម។

អ្វីដែលគួរឲ្យចាប់អារម្មណ៍បន្ថែមលើសមិទ្ធផលដែលសម្រេចបាន គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុលីមីតធីត បានធ្វើដំឡើងឋានៈ និងតួនាទីដល់បុគ្គលិកចំនួន ១៥រូប (១៦%) ក្នុងឆ្នាំ២០១៨នេះ។

## ការអភិវឌ្ឍចំណេះជំនាញដល់បុគ្គលិក

គោលដៅធនធានមនុស្សរបស់គ្រឹះស្ថាន ខេមា គឺកសាងក្រុមដ៏ខ្លាំងក្លាមួយ និងមើលឃើញបុគ្គលិករបស់យើងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ខណៈពេលដែល ខេមា កំពុងរីកចម្រើនលូតលាស់ទៅមុខ។ ខេមា មានបំណងកសាងក្រុមការងារដែលមានចំណេះជំនាញ និងបង្ហាញពីកម្រិតនៃការសហការខ្ពស់ក្នុងការអភិវឌ្ឍ ដើម្បីទទួលបាននូវលទ្ធផលល្អទាក់ទងទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់យើង។

សម្រាប់ឆ្នាំ ២០១៨ នេះដែរ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានផ្តល់នូវវគ្គបណ្តុះបណ្តាលសរុបចំនួន ៩មុខវិជ្ជា ទៅដល់បុគ្គលិកចំនួន ៩៧រូប ដែលរួមមានជំនាញបច្ចេកទេស ជំនាញពាក់ព័ន្ធនឹងការអនុវត្តប្រចាំថ្ងៃ ជំនាញពាក់ព័ន្ធនឹងឥរិយាបទធ្វើការព្រមទាំងជំនាញគ្រប់គ្រង និងដឹកនាំ។ ការអភិវឌ្ឍចំណេះជំនាញរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ គឺដើម្បីឲ្យមានលក្ខណៈសមស្របទីផ្សារធនាគារ និងមីក្រូហិរញ្ញវត្ថុ និងបរិបទនៃយុទ្ធសាស្ត្ររីកចម្រើនរបស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ផងដែរ។ ជារៀងរាល់ឆ្នាំ ខេមា បានបញ្ជូនបុគ្គលិកឲ្យចូលរួមវគ្គបណ្តុះបណ្តាលវគ្គខ្លីដែលបានរៀបចំដោយស្ថាប័នខាងក្រៅជាច្រើនទៀត ក្នុងគោលបំណងដើម្បីកសាងសមត្ថភាពបន្ថែមទៀតក្នុងការដឹកនាំគ្រឹះស្ថាន ខេមា ឲ្យមានភាពរលូត និងប្រកបដោយប្រសិទ្ធភាពខ្ពស់ហើយលើសពីនេះទៀតបានគាំទ្រ និងបន្តផ្តល់អាហារូបករណ៍ដល់បុគ្គលិកគ្រប់លំដាប់ថ្នាក់ទាំងអស់។

| សូចនាករ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ចំនួនបុគ្គលិកសរុប | ៥៦ | ៧៩ | ៩៤ | ៩៥ |
| ចំនួនបុគ្គលិកឥណទានសរុប | ២៩ | ៣៨ | ៤៨ | ៤៦ |
| ភាគរយ (%) បុគ្គលិកស្រី | ៣០% | ២៨% | ២៨% | ២៨% |
| ភាគរយ (%) បុគ្គលិកប្រុស | ៧០% | ៧២% | ៧២% | ៧២% |



## សុខុមាលភាពរបស់បុគ្គលិក

ក្នុងនាមគណៈគ្រប់គ្រងរបស់ ខេមាក៏នៅតែបន្តព្យាយាមផ្តល់បរិយាកាសការងារមួយដ៏អស្ចារ្យ និងរីករាយដែលបុគ្គលិករបស់យើងអាចមានការអភិវឌ្ឍ និងការលូតលាស់ ជាស្ថាប័នដែលមានវប្បធម៌ដ៏រឹងមាំក្នុងការលើកកម្ពស់ការធ្វើការជាក្រុម ក្នុងគោលបំណងពង្រឹងទំនាក់ទំនងរវាងថ្នាក់គ្រប់គ្រង និងបុគ្គលិកនៅការិយាល័យកណ្តាល និងគ្រប់សាខាទាំងអស់របស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត តាមរយៈសកម្មភាព សំខាន់ៗ ជាច្រើនដែលបានផ្តួចផ្តើម និងបង្កើតឡើងក្នុងឆ្នាំនីមួយៗ។ យើងស្រលាញ់បុគ្គលិករបស់យើងផលិតផល និងសេវាកម្មរបស់យើងសហគមន៍យើង និងសង្គមដែលយើងធ្វើការជាមួយ។





## ការផ្តល់ឱកាសដល់និស្សិតចុះកម្មសិក្សា

ក្នុងឆ្នាំ២០១៨នេះគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានអនុញ្ញាតឲ្យនិស្សិតចំនួន ០៥ក្រុម ដែលមានសមាជិក ២២រូប (និស្សិតស្រី ១២រូប) ដើម្បីសរសេរនិក្ខេបបទ និងចុះកម្មសិក្សា ក្នុងគោលបំណង ទទួល បានបទពិសោធន៍ផងដែរតាមរយៈការផ្តល់ឱកាសដល់និស្សិតដើម្បីហាត់ការ និងធ្វើការងារស្ម័គ្រចិត្ត ក្នុងគ្រឹះស្ថានផងដែរ ។





# ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ការត្រួតពិនិត្យផ្ទៃក្នុងគឺ ជាកត្តាចំបងដែលជួយឲ្យប្រតិបត្តិការរបស់គ្រឹះស្ថានទទួលជោគជ័យ និង សម្រេចតាមផែនការអាជីវកម្មរបស់ខ្លួន។ ភាពទន់ខ្សោយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបានធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាច្រើនទទួលរងនៅការខាតបង់។ ខេមា បានបង្កើតនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំដែលជួយជំរុញឲ្យ ប្រតិបត្តិការអាជីវកម្មឲ្យមានប្រសិទ្ធិភាពសម្រាប់ការពារទ្រព្យសកម្ម តាមរយៈកាត់បន្ថយនូវកំហុសខុសឆ្គងដែលបានកើតឡើងដោយចេតនា ឬអចេតនារបស់បុគ្គលិកដែលបានអនុវត្តន៍ការងារទៅតាមគោលការណ៍ និងនីតិវិធីព្រមទាំងសេចក្តីសម្រេចផ្សេងៗរបស់គ្រឹះស្ថាន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់ខេមា ទាំងអស់ត្រូវបានដាក់ចេញឲ្យអនុវត្ត ដើម្បីធ្វើការកាត់បន្ថយនិងទប់ស្កាត់ហានិភ័យដែលប៉ះពាល់របស់គ្រឹះស្ថាន ដូចជាការបែងចែកកាតព្វកិច្ច និងការទទួលខុសត្រូវ ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ។ គណៈគ្រប់គ្រងប្រតិបត្តិ នាយកការិយាល័យសាខា និងបុគ្គលិកទាំងអស់ជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងគ្រប់គ្រងហានិភ័យប្រចាំថ្ងៃរបស់គ្រឹះស្ថាន។ ក្រុមប្រឹក្សាភិបាល បានបង្កើនគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថាន និងត្រួតពិនិត្យមើលពីប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ របស់គ្រឹះស្ថានជាប្រចាំ។ ឆ្នាំ២០១៥ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតដើម្បីធ្វើឲ្យការត្រួតពិនិត្យផ្ទៃក្នុង មានប្រសិទ្ធិភាពដោយកំណត់នូវតួនាទី និងភារៈកិច្ចបានច្បាស់លាស់សម្រាប់ធ្វើការវាយតម្លៃហានិភ័យ ដោយឯករាជ្យលើភាពគ្រប់គ្រង និងប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអនុវត្តន៍ដោយថ្នាក់គ្រប់គ្រងរបស់ខេមា។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងរាយការណ៍ ទៅគណៈកម្មការសវនកម្មដែលជាថ្នាក់ក្រុមប្រឹក្សាភិបាដោយផ្ទាល់។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពី «ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុ» ចំពោះការរៀបចំរចនាសម្ព័ន្ធនៃ សវនកម្មផ្ទៃក្នុងមានគោលបំណងនាំមុខងារសវនកម្មផ្ទៃក្នុងជា ធនធានយុទ្ធសាស្រ្ត និងនីតិវិធីសវនកម្ម។ លើសពីនេះទៀតនាយកដ្ឋានអនុវត្តការងារត្រួតពិនិត្យដោយផ្អែកលើបទដ្ឋានអន្តរជាតិសម្រាប់អនុវត្តវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង។ ចុងឆ្នាំ២០១៨ នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានបុគ្គលិកចំនួន៣នាក់ ដោយមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់គណៈកម្មការសវនកម្ម ថ្នាក់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងទាំងអស់។ នៅតាមការិយាល័យសាខានីមួយៗ សវនករផ្ទៃក្នុងតែងតែធ្វើការចុះត្រួតពិនិត្យជាប្រចាំទៅលើការ គ្រប់គ្រងគុណភាពនៃសម្ភាធឥណទាន គុណភាពសេវាបម្រើអតិថិជនប្រតិបត្តិការគ្រប់គ្រងសាច់ប្រាក់ និងការចំណាយទូទៅរបស់ការិយាល័យសាខា។ ឆ្នាំ២០១៨ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានបញ្ចប់ ១៩ កិច្ចការ

សវនកម្ម ដោយគ្របដណ្តប់ការធ្វើសវកម្មលើគ្រប់ប្រតិបត្តិការសំខាន់ៗ។ សវនករផ្ទៃក្នុងបានចុះធ្វើការត្រួតពិនិត្យកម្ចីនៅតាមការិយាល័យ សាខាបានចំនួន ៤១៤នាក់ ស្មើនឹង ២៥,៨៤% នៃគណនីឥណទានចំនួនសរុប ដើម្បីធ្វើការវាយតម្លៃគុណភាពឥណទាន និងបញ្ជាក់ថាមានការបញ្ចេញឥណទានអនុលោមតាមគោលការណ៍ និងនីតិវិធីរបស់ស្ថាប័នដែលបានកំណត់។ លទ្ធផលសវនកម្ម និងសមិទ្ធផលប្រចាំឆ្នាំ២០១៨របស់ខេមាបង្ហាញថាឥណទានដែលបានផ្តល់ឲ្យ អតិថិជនអនុលោមតាមគោលការណ៍ និងនីតិវិធីនានា និងមានគុណភាពឥណទានល្អ។ បុគ្គលិកតាមការិយាល័យ សាខាបានបំពេញការងាររបស់ខ្លួនបានល្អប្រសើរ និងបានអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងមានប្រសិទ្ធភាពផងដែរ។



# ការទទួលខុសត្រូវចំពោះសង្គម និងបរិស្ថាន

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត យកចិត្តទុកដាក់ខ្ពស់លើកិច្ចការងារបរិស្ថាន និងសង្គម ដោយធ្វើការវិភាគសិក្សាស្រាវជ្រាវ និងតាមដានការអនុវត្តការងារជាក់ស្តែង ធៀបនឹងគោលការណ៍ នីតិវិធី ទម្រង់គំរូ និងសេចក្តីណែនាំនានា ព្រមទាំង ទប់ស្កាត់ឲ្យទាន់ពេលវេលា ដើម្បីធានាឲ្យប្រាកដថា រាល់ការផ្តល់ឥណទានរបស់ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត មិនមានផលប៉ះពាល់ដល់បរិស្ថាន សង្គម និងច្បាប់។ ក្នុងនោះផងដែរមាន នាយកដ្ឋាន ឥណទាន និងការិយាល័យ សាខារបស់ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក៏បានចុះសិក្សា វិភាគវាយតម្លៃឥណទាន ដោយផ្តោតសំខាន់ផងដែរនូវកំរិតហានិភ័យ ផលប៉ះពាល់បរិស្ថាន ដល់ទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន(មុនពេលផ្តល់ឥណទាន) និងសិក្សាស្វែងយល់រាល់ឧបទ្ទវហេតុ ឬនិន្នាការដែលអាចជាសញ្ញាគ្រោះថ្នាក់ និងបង្កការខូចខាត សង្គម និង បរិស្ថាន និងផលប្រយោជន៍របស់គ្រឹះស្ថាន ខេមា ផងដែរ។ យើងក៏បានផ្តល់ការហ្វឹកហ្វឺនដល់ការិយាល័យសាខា ដោយធ្វើការបកស្រាយ ពន្យល់ នូវរាល់ចម្ងល់ផ្សេងៗទៅលើចំណេះដឹងស្តីពី សង្គម និង បរិស្ថាន ដើម្បីចូលរួមលើកស្ទួយនិរន្តរភាពរបស់ គ្រឹះស្ថាន ខេមា និង សង្គម ដែលពាក់ព័ន្ធនឹងសកម្មភាពផ្តល់ ឥណទាន របស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ។





# របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលគ្រឹះស្ថានខេមាមីក្រូហិរញ្ញវត្ថុលីមីធីត (ហៅកាត់ថា "ក្រុមហ៊ុន") បានដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

## សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុទូលំទូលាយប្រកដោយនិរន្តរភាព និងប្រសិទ្ធភាពទៅដល់សហគ្រិនធុនតូច និងមធ្យម ដែលជាកសិករ សិប្បករ និងអាជីវករ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលនៅខាងក្រោមនេះ៖

| | ២០១៧ | | ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញមុនពន្ធលើប្រាក់ចំណូល | ២០០.២៦២ | ៨០៤.៦៥៥ | ២០៧.១៥៩ | ៨៣៦.៣០១ |
| ចំណាយពន្ធលើចំណូល | (៥៣.៧០៣) | (២១៥.៧៧៩) | (៥៨.៥៨១) | (២៣៦.៤៩២) |
| ចំណេញក្នុងឆ្នាំ | ១៤៦.៥៥៩ | ៥៨៨.៨៧៦ | ១៤៨.៥៧៨ | ៥៩៩.៨០៩ |

## ដើមទុនភាគហ៊ុន

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានអនុម័តបោះផ្សាយភាគហ៊ុនបន្ថែមចំនួន១.០៥០.០០០ភាគហ៊ុន និងមានតម្លៃ ១.០៥០.០០០ ដុល្លារអាមេរិក។ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៥ ផងដែលក្រុមហ៊ុនបានទទួលការអនុម័តពីធនាគារជាតិ នៃកម្ពុជាឲ្យបង្កើនដើមទុនរបស់ក្រុមហ៊ុនពី ១.០៥៣.០០០ ដុល្លារអាមេរិច ទៅ ២.១០៣.០០០ ដុល្លារអាមេរិក តាមរយៈការបន្ថែមសាច់ប្រាក់ចំនួន ៨៥០.០០០ ដុល្លារអាមេរិក និងការផ្ទេរពីប្រាក់ចំណេញរក្សាទុកចំនួន ២០០.០០០ ដុល្លារអាមេរិក។ ការធ្វើវិសោធនកម្មលក្ខន្តិកៈ របស់ក្រុមហ៊ុនត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨។

## ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋាន សមស្រប ពាក់ព័ន្ធទៅនឹងការជម្រះហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ចេញពីបញ្ជី និងការធ្វើសំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ទាំងអស់ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនពេញលេញ ចំពោះហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពី កាលៈទេសៈណាមួយដែលនាំឱ្យចំនួនហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់និងសង្ស័យដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់នោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋាន សមស្របដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចបង្វិលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថា អាចនឹងបង្វិលមកវិញបាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ពុំត្រឹមត្រូវជាសារវន្តនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក ឬ

ខ. បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំមក ក្រៅពីអ្វីដែលបានកើតឡើងនៅក្នុងដំណើរការអាជីវកម្មធម្មតា។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនបានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹងឬ

អាចនឹងមានផលប៉ះពាល់ជាសារវន្ត ដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលប្រតិបត្តិការ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះ ឱ្យមានភាពស៊ីសង្វាក់គ្នា។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន និងគោលការណ៍ណែនាំដែលចេញផ្សាយដោយធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា ឬ ប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធិភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មត សមស្របថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មក្នុងពេលអនាគតដ៏ខ្លី និង

៥. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តសំខាន់ៗ ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយធានាថាវាត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងឆ្នាំនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយឡើយ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលពីដំណាច់ឆ្នាំ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមានខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងឆ្នាំនេះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការក្នុងអំឡុងឆ្នាំ និងគិតត្រឹមកាលបរិច្ឆេទនៃរបាយការនេះមានរាយនាមដូចខាងក្រោម៖

- លោក ធន់ វឌ្ឍនា ប្រធានក្រុមប្រឹក្សាភិបាល
- លោកស្រី ខាត់ សុខគាន អនុប្រធានក្រុមប្រឹក្សាភិបាល
- លោក ខូវ សូវៀត អភិបាល

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយដែលបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំ ចេញដោយធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

លោក ធន់ វឌ្ឍនា
ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី ឌិត នីតា
អគ្គនាយិកាប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩

# របាយការណ៍សវនករឯករាជ្យ

## មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត (ហៅកាត់ថា"ក្រុមហ៊ុន") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលរបស់ហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំច្បាស់លាស់ពីធនាគារជាតិ នៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") និងស្តង់ដារគណនេយ្យកម្ពុជា។

## របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

## មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារអន្តរជាតិ ស្តីពី សវនកម្មនៃកម្ពុជា (ហៅកាត់ថា"ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ "ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផលដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀតដែលកំណត់ដោយ "ក្រមសីលធម៌អន្តរជាតិ" និង ក្រមសីលធម៌ វគសក។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំទទួលបាននាកាលបរិច្ឆេទរបាយការណ៍សវនករនេះ រួមមានរបាយការណ៍ក្រុមប្រឹក្សាភិបាល និងឧបសម្ព័ន្ធស្ដីពីតម្រូវការនៃប្រកាសរបស់ធនាគារ កណ្ដាលប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករ របស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្ដប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ទៅលើព័ត៌មានផ្សេងៗដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ច របាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃ កម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្ដាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬ បញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## មតិយោបល់របស់យើងខ្ញុំ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារ សវនកម្មតែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាភាពមន្ទិលឆ្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំវាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមានការសមគំនិតការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀតយើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំអាស្រ័យទៅ

លើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឲ្យក្រុមហ៊ុនឈប់បន្តនិរន្តរភាពអាជីវកម្ម។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែងដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជាទំហំការងារ និងពេលវេលាសវនកម្មព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

ជ. ក្រុមហ៊ុន PricewaterhouseCoopers (Cambodia) Ltd.

ឡាង ហ៊ី

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ៖ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩

# របាយការណ៍ហិរញ្ញវត្ថុ

## តារាងតុល្យការ

*គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| បរិយាយ | កំណត់សម្គាល់ | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១៨៦.៧០៦ | ៧៥០.១៨៥ | ១៤៨.៤៩៤ | ៥៩៩.៤៧០ |
| សមតុល្យនៅធនាគារកណ្តាល | ៥ | ១០៦.៥៩៣ | ៤២៨.២៩១ | ១០៥.៨៣៣ | ៤២៧.២៤៨ |
| សមតុល្យនៅធនាគារផ្សេងៗ | ៦ | ៦៦២.៥៦៦ | ២.៦៦២.១៩០ | ២៦.៩៥១ | ១០៨.៨០១ |
| ឥណទាននិងបុរេប្រទានអតិថិជន | ៧ | ១០.០៦១.៧៩៧ | ៤០.៤២៨.៣០០ | ៧.៥៩២.១៩៨ | ៣០.៦៤៩.៧០៣ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ១៥៥.០៨៨ | ៦២៣.១៤៣ | ១២២.៤៥២ | ៤៩៤.៣៣៩ |
| ពន្ធពន្យារទ្រព្យសកម្ម | ១១(ក) | ៦៣.១០៣ | ២៥៣.៥៤៨ | ៣០.៤៤៨ | ១២២.៩១៩ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ៣០.២០៥ | ១២១.៣៦៤ | ៥៩.៩៣៨ | ២៤១.៩៧០ |
| ទ្រព្យសកម្មអរូបី | ១០ | ៣១.០៨៥ | ១២៤.៩០០ | ៤៣.៤៤២ | ១៧៥.៣៧៥ |
| ទ្រព្យសកម្មសរុប | | ១១.២៩៧.១៤៣ | ៤៥.៣៩១.៩២១ | ៨.១២៩.៧៥៦ | ៣២.៨១៩.៨២៥ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១២ | ៣៧១.៦៩៩ | ១.៤៩៣.៤៨៧ | ១៥៦.៤៣៨ | ៦៣១.៥៤១ |
| ប្រាក់កម្ចី | ១៣ | ៨.០៨៩.៣៩៤ | ៣២.៥០៣.១៨៥ | ៥.៣១៨.៩៧៥ | ២១.៤៧២.៧០២ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | | ៨៨.០២១ | ៣៥៣.៦៦៨ | ៥២.៨៧៣ | ២១៣.៤៤៨ |
| បំណុលសរុប | | ៨.៥៤៩.១១៤ | ៣៤.៣៥០.៣៤០ | ៥.៥២៨.២៨៦ | ២២.៣១៧.៦៩១ |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | ២.១០៣.០០០ | ៨.៤៤៩.៨៥៤ | ២.១០៣.០០០ | ៨.៤៨៩.៨១១ |
| ប្រាក់ចំណេញរក្សាទុក | | ៦៤៥.០២៩ | ២.៥៩១.៧២៧ | ៤៩៨.៤៧០ | ២.០១២.៣២៣ |
| មូលធនសរុប | | ២.៧៤៨.០២៩ | ១១.០៤១.៥៨១ | ២.៦០១.៤៧០ | ១០.៥០២.១៣៤ |
| បំណុល និងមូលធនសរុប | | ១១.២៩៧.១៤៣ | ៤៥.៣៩១.៩២១ | ៨.១២៩.៧៥៦ | ៣២.៨១៩.៨២៥ |

## របាយការណ៍លទ្ធផល

*សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| បរិយាយ | កំណត់សម្គាល់ | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១៥ | ១.៥៣២.៣៣៥ | ៦.១៥៦.៩២២ | ១.៤៤៤.១៦៩ | ៥.៨៣០.១១០ |
| ចំណាយការប្រាក់ | | (៤៨២.៩៦៥) | (១.៩៤០.៥៥៣) | (៤៥០.៤៧៦) | (១.៨១៨.៥៧១) |
| ចំណូលការប្រាក់សុទ្ធ | | ១.០៤៩.៣៧០ | ៤.២១៦.៣៦៩ | ៩៩៣.៦៩៣ | ៤.០១១.៥៣៩ |
| សំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុ | ១៦ | (១២៥.៣២៤) | (៥០៣.៥៥១) | (១០៨.៨២៩) | (៤៣៩.៣៤៣) |
| ចំណូលការប្រាក់សុទ្ធ បន្ទាប់ពីសំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុ | | ៩២៤.០៤៦ | ៣.៧១២.៨១៨ | ៨៨៤.៨៦៤ | ៣.៥៧២.១៩៦ |
| ចំណូលកម្រៃជើងសា | ១៧ | ១៦៨.៥៤២ | ៦៧៧.២០២ | ១០៨.៩២៣ | ៤៣៩.៦៨៦ |
| ចំណូលផ្សេងៗ | ១៨ | ១៧.០៧៣ | ៦៨.៥៩៩ | ៣១.២៨៧ | ១២៦.៣៤២ |
| ចំណូលប្រតិបត្តិការសរុប | | ១.១០៩.៦៦១ | ៤.៤៥៨.៦១៩ | ១.០២៥.០៧៤ | ៤.១៣៨.២២៤ |
| ចំណាយបុគ្គលិក | ១៩ | (៦០១.០៨២) | (២.៤១៥.១៤៧) | (៤៩១.៩១៣) | (១.៩៨៥.៨៥៣) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២០ | (២៦០.៦៦៨) | (១.០៤៧.៣៦៤) | (២៧៤.៦៥៧) | (១.១០៨.៧៩០) |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | (៣៥.២៩២) | (១៤១.៨០៣) | (៤៥.៩៥៤) | (១៨៥.៥១៦) |
| រំលស់ទ្រព្យសកម្មអរូបី | ១០ | (១២.៣៥៧) | (៤៩.៦៥០) | (៥.៣៩១) | (២១.៧៦៤) |
| | | (៩០៩.៣៩៩) | (៣.៦៥៣.៩៦៤) | (៨១៧.៩១៥) | (៣.៣០១.៩២៣) |
| ចំណេញមុនពន្ធលើប្រាក់ចំណូល | | ២០០.២៦២ | ៨០៤.៦៥៥ | ២០៧.១៥៩ | ៨៣៦.៣០១ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១១ | (៥៣.៧០៣) | (២១៥.៧៧៩) | (៥៨.៥៨១) | (២៣៦.៤៩២) |
| ចំណេញក្នុងឆ្នាំ | | ១៤៦.៥៥៩ | ៥៨៨.៨៧៦ | ១៤៨.៥៧៨ | ៥៩៩.៨០៩ |
| ចំណេញត្រូវបែងចែកឲ្យម្ចាស់ក្រុមហ៊ុន | | ១៤៦.៥៥៩ | ៥៨៨.៨៧៦ | ១៤៨.៥៧៨ | ៥៩៩.៨០៩ |

## របាយការណ៍លំហូរសាច់ប្រាក់

*សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| បរិយាយ | កំណត់សម្គាល់ | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធ(បានប្រើក្នុង)/ បានពីសកម្មភាពប្រតិបត្តិការ | ២១ | (២.០៨៣.៥៧៩) | (៨.៣៧១.៨២១) | ១៨.៤១៧ | ៧៤.៣៤៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | (៥.៥៥៩) | (២២.៣៣៦) | (៤៣.៤៣៥) | (១៧៥.៣៤៧) |
| ការទិញទ្រព្យសកម្មអរូបី | | - | - | (៤៨.៧៨៥) | (១៩៦.៩៤៥) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៥.៥៥៩) | (២២.៣៣៦) | (៩២.២២០) | (៣៧២.២៩២) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១០.៧៧១.០៥២ | ៤៣.២៧៨.០៨៨ | ៧.២០៥.១១១ | ២៩.០៨៧.០៣៣ |
| ការសងប្រាក់កម្ចី | | (៨.០០០.៦៣៤) | (៣២.១៤៦.៥៤៧) | (៦.៩០៩.៦០៨) | (២៧.៨៩៤.០៨៨) |
| ការបែងចែកភាគលាភ | | - | - | (១៥០.០០០) | (៦០៥.៥៥០) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ២.៧៧០.៤១៨ | ១១.១៣១.៥៤១ | ១៤៥.៥០៣ | ៥៨៧.៣៩៥ |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់ សមមូលសុទ្ធ** | | ៦៨១.២៨០ | ២.៧៣៧.៣៨៤ | ៧១.៧០០ | ២៨៩.៤៥២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ១៧៦.១២៨ | ៧១១.០២៨ | ១០៤.៤២៨ | ៤២១.៥៧៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៣.៣៤៧) | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល ចុងឆ្នាំ** | ២២ | ៨៥៧.៤០៨ | ៣.៤៤៥.០៦៥ | ១៧៦.១២៨ | ៧១១.០២៨ |

## របាយការណ៍បម្រែបម្រួលមូលធន

*សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| បរិយាយ | ត្រូវបែងចែកឲ្យម្ចាស់ក្រុមហ៊ុន | | |
|---|---|---|---|
| | ប្រាក់ចំណេញ | | |
| | ដើមទុន ដុល្លារអាមេរិក | រក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ២.១០៣.០០០ | ៤៩៩.៨៩២ | ២.៦០២.៨៩២ |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | ១៤៨.៥៧៨ | ១៤៨.៥៧៨ |
| ការបែងចែកភាគលាភ | - | (១៥០.០០០) | (១៥០.០០០) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ២.១០៣.០០០ | ៤៩៨.៤៧០ | ២.៦០១.៤៧០ |
| គិតជាពាន់រៀល | ៨.៤៨៩.៨១១ | ២.០១២.៣២៣ | ១០.៥០២.១៣៤ |
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ២.១០៣.០០០ | ៤៩៨.៤៧០ | ២.៦០១.៤៧០ |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | ១៤៦.៥៥៩ | ១៤៦.៥៥៩ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ២.១០៣.០០០ | ៦៤៥.០២៩ | ២.៧៤៨.០២៩ |
| គិតជាពាន់រៀល | ៨.៤៤៩.៨៥៤ | ២.៥៩១.៧២៧ | ១១.០៤១.៥៨១ |






## រាជធានីភ្នំពេញ

*ការិយាល័យកណ្តាល*

ផ្ទះលេខ ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១
ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ទូរស័ព្ទ៖ (+៨៥៥)២៣ ៩៩៦ ៩៣៦ / ៥៣៣ ៩៩៩៩
អ៊ីម៉ែល ៖ info@camma.com.kh
គេហទំព័រ ៖ www.camma.com.kh

*សាខាអង្គស្នួល*

ផ្ទះលេខ ៣៨អា១ ផ្លូវជាតិលេខ៤ ភូមិស្វាយជ្រំ ឃុំ
បែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ។
ទូរស័ព្ទ៖ (+៨៥៥)៨៩ ៩៩៩ ១៧៤
អ៊ីម៉ែល ៖ ans@camma.com.kh







*សាខាក្រុងតាខ្មៅ*

ផ្ទះលេខ (គ្មាន) ផ្លូវជាតិលេខ ១១៥ ភូមិព្រែកសំរោង សង្កាត់
តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។
ទូរស័ព្ទ៖ (+៨៥៥)៨៩ ៦៦៦ ០០៣
អ៊ីម៉ែល ៖ tkm@camma.com.kh